# សតិប្បដ្ឋានសូត្រ



សតិប្បដ្ឋានសូត្រ

# អារម្ភកថា

ខ្ញុំព្រះករុណា ខ្ញុំបាទបានទទួលច្បាប់ដើមជាធម្មទានអំពីលោកគ្រូធម្មាចារ្យ ជឹម ជំនិត មកអាន ហើយក៏បានឃើញនូវការគូសលប់ ដិតដាម និងជួសជុល ព្រមទាំងមានភាគខ្លះរលប់ មើលពុំច្បាស់ផង។ ទើបខ្ញុំព្រះករុណា ខ្ញុំបាទ ពិគ្រោះជាមួយលោកគ្រូ ជឹម ជំនិត ដើម្បីរៀបចំបោះពុម្ពសារជាថ្មី ដោយពង្រីកតួអក្សរឲ្យបានធំល្មមងាយស្រួលសម្រាប់ពុទ្ធបរិស័ទខ្មែរយើង ទោះបីលោកមានវ័យចាស់ក៏លោកអាចអានសៀវភៅ **សតិប្បដ្ឋាន** នេះបាន។

**-សូមឲ្យព្រះសាសនាបានរុងរឿងចម្រើន** !

**-សូមឲ្យព្រះពុទ្ធសាសនាផ្សាយទូទៅពេញសាកលលោក** !

**-សូមឲ្យលោកទាំងមូលបានប្រកបដោយសន្តិភាព** !

**-ព្រះសក្យមុនីសម្ពុទ្ធទ្រង់ត្រាស់ថា "នត្ថិ សន្តិ បរំសុខំ"**

**ពុំមានសេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ ។**

**សូមអនុមោទនា** !!!

វត្តធម្មសាមគ្គី ថ្ងៃ១៥កើត ខែមាឃ ព.ស. ២៥៥៣

ត្រូវនឹងថ្ងៃអាទិត្យទី ៣០ ខែមករា ឆ្នាំ២០១០


Websites: WatKhemaraRatanaram.org or WatKhmers.org

# សតិបដ្ឋានសុត្ត

## ឧទ្ទេសវារកថា

**ឯវម្មេ សុតំ** សូត្រនេះឈ្មោះ "**សតិបដ្ឋានសូត្រ**" ដែលខ្ញុំ អានន្ទ បានស្តាប់មកយ៉ាងនេះ ថា ៖

**ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្មំ នាម កុរូនំ និគមោ៕**

សម័យមួយព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់នៅក្នុងដែនកុរុទ្រង់អាស្រ័យ នៅកម្មាសធម្មនិគមនៃអ្នកដែនកុរុ ទាំងឡាយជាទីគោចរ។

**តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ**

ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា "ម្នាលភិក្ខុទាំងឡាយ"

**ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ៕**

ភិក្ខុទាំងឡាយនោះ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា "សូមទ្រង់ព្រះមេត្តាប្រោស"។

**ភគវា ឯតទវោច ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិបដ្ឋានា៕**

ទើបព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ព្រះពុទ្ធដីការនេះថា ម្នាលភិក្ខុទាំងឡាយផ្លូវគឺ សតិបដ្ឋាន ទាំងឡាយ ៤នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីស្អាតវិសេសដល់សត្វទាំងឡាយ ដើម្បីកន្លងបង់នូវសោក និងខ្សឹបខ្សួលរំជួលចិត្តទាំងឡាយ ដើម្បីអស្តង្គតរលត់ទៅនៃទុក្ខ និងទោមនស្សទាំងឡាយ ដើម្បីដល់នូវអរិយគ្គ ជាធម៌ស្រោចស្រង់សត្វ


Websites: WatKhemaraRatanaram.org or WatKhmers.org

ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន។

**កតមេ ចត្តារោ?** សតិបដ្ឋានទាំងឡាយ ៤គឺអ្វីខ្លះ?

**ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោសតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វមានស្មារតីជាគ្រឿងកំណត់ បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។

**វេទនាសុ វេទនានុបស្សី វិហរតិ អាតាបីសម្បជានោ សតិមា វិនេយ្យលោកេ អភិជ្ឈាទោមនស្សំ។**

ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេសប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។

**ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យលោកេ អភិជ្ឈាទោមនស្សំ ។**

ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេសប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បណ្តេញបង់នូវអភិជ្ឈា និងទោមនស្ស ក្នុងលោក។

“**ឧទ្ទេសវារកថា និដ្ឋិតា**”

( ឧទ្ទេសវារកថា ចប់)



Websites: WatKhemaraRatanaram.org or WatKhmers.org

# កាយានុបស្សនាសតិបដ្ឋាន

((មាន ៦ បព្វៈ))

កថញ្ច ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ? ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ?

## ១- អានាបានបព្វ

**ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វានិសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតិ ឧបដ្ឋបេត្វា** ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះនៅក្នុងអរញ្ញសេនាសនៈក្តី នៅក្នុងរុក្ខមូលសេនាសនៈក្តី នៅក្នុងសុញ្ញាគារសេនាសនៈក្តី ហើយអង្គុយពត់ភ្នែនតម្រង់កាយប្រុងស្មារតី ឲ្យមានមុខឆ្ពោះទៅកាន់ព្រះកម្មដ្ឋាន ។

**សោ សតោ វ អស្សសតិ សតោ បស្សសតិ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ ។**

ភិក្ខុនោះ មានស្មារតីដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល ទោះដកដង្ហើមចូលវែងដឹងច្បាស់ថា "អញដកដង្ហើមចូលវែង" ទោះដកដង្ហើមចេញខ្លី ដឹងច្បាស់ថា "អញដកដង្ហើមចេញខ្លី" ទោះដកដង្ហើមចូលខ្លី ដឹងច្បាស់ថា "អញដកដង្ហើមចូលខ្លី" ។

**សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទីបស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។**

សិក្សាថា "អញដឹងឲ្យច្បាស់សព្វពួកខ្យល់អស្សាសៈ សឹមដកដង្ហើម



Websites: WatKhemaraRatanaram.org or WatKhmers.org

ចេញ″ សិក្សាថា ‶អញដឹងឲ្យច្បាស់សព្វពួកខ្យល់បស្សាសៈសឹមដកដង្ហើមចូល″ សិក្សាថា ‶អញរម្ងាប់នូវកាយសង្ខារ (ដែលគ្រោតគ្រាត) សឹមដកដង្ហើមចេញ″ សិក្សាថា ‶អញរម្ងាប់នូវកាយសង្ខារ (ដែលគ្រោតគ្រាត) សឹមដកដង្ហើមចូល″។

**សេយ្យថាបិ ភិក្ខវេ ទក្ខោ ភមការោ វា ភមការន្តេវាសី វា ទីឃំ វា អញ្ឆន្តោ ទីឃំ អញ្ឆាមីតិ បជានាតិ រស្សំ វា អញ្ឆន្តោ រស្សំ អញ្ឆាមីតិ បជានាតិ ៕**

ម្នាលភិក្ខុទាំងឡាយ យ៉ាងដូចម្តេចមិញ ជាងក្រឡឹងដែលប៉ិនប្រសប់ក្តី កូនសិស្សនៃជាងក្រឡឹងក្តីទោះទាញខ្សែក្រឡឹងវែង ដឹងច្បាស់ថា ‶អញទាញខ្សែក្រឡឹងវែង″ ទោះទាញខ្សែក្រឡឹងខ្លីដឹងច្បាស់ថា ‶អញទាញខ្សែក្រឡឹងខ្លី″ ។

**ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ៕ល៕ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ៕**

ម្នាលភិក្ខុទាំងឡាយ យ៉ាងដូច្នោះឯង ភិក្ខុ (ក្នុងសាសនានេះ) ទោះដកដង្ហើមចេញវែង ដឹងច្បាស់ថា ‶អញដកដង្ហើមចេញវែង″។ល។ ទោះដកដង្ហើមចូលខ្លីដឹងច្បាស់ថា ‶អញដកដង្ហើមចូលខ្លី″។

**សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ៕ល៕ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ៕**

សិក្សាថា ‶អញដឹងឲ្យច្បាស់សព្វពួកខ្យល់អស្សាសៈសឹមដកដង្ហើមចេញ″ ។ល។ សិក្សាថា ‶អញរម្ងាប់នូវកាយសង្ខារ (ដែលគ្រោតគ្រាត) សឹមដកដង្ហើមចូល″។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ពហិទ្ធា វា កាយេ**


Websites: WatKhemaraRatanaram.org or WatKhmers.org

**កាយានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា កាយេ កាយានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា កាយស្មឹ វិហរតិ វយធម្មានុបស្សី វា កាយស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា កាយស្មឹ វិហរតិ។ អត្ថិ កាយោតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវ ទេវ ញាណមត្តាយ បតិស្សតិ មត្តាយ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិលោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្រៅ (របស់អ្នកដទៃ) ផងពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ទាំងខាងក្នុងទាំងខាងក្រៅផង ពិចារណាឃើញរឿយៗ នូវធម៌ ដែលប្រជុំកើតឡើងក្នុងកាយផង ពិចារណាឃើញរឿយៗ នូវធមតដែលសូន្យទៅក្នុងកាយផង ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងទាំងធម៌ដែលសូន្យទៅក្នុងកាយផង។ ម្យ៉ាងទៀតស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា "គ្រាន់តែជាកាយ" (មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី និងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ។**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងដែលហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

"**អានាបានបព្វំ និដ្ឋិតំ**"

( ពួកខ្យល់ដង្ហើមចេញចូល ចប់)

# ២- ឥរិយាបថបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ ឋិតោ វា ឋិតោម្ហីតិ បជានាតិ និសិន្នោ វា និសិន្នោម្ហីតិ បជានាតិ សយានោ វា សយានោម្ហីតិ បជានាតិ យថា យថា វាបនស្ស កាយោ បណិហិតោ ហោតិ តថា តថា នប្បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) ទោះដើរ ដឹងច្បាស់ថា "អញដើរ" ទោះឈរ ដឹងច្បាស់ថា "អញឈរ" ទោះអង្គុយ ដឹងច្បាស់ថា "អញអង្គុយ" ទោះដេក ដឹងច្បាស់ថា "អញដេក" ទោះកាយរបស់ភិក្ខុនោះតម្កល់នៅដោយអាការយ៉ាងណាៗ ក៏ដឹងច្បាស់នូវកាយនោះដោយអាការយ៉ាងនោះៗ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ល។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ។

“**ឥរិយាបថបព្វំ និដ្ឋិតំ**”

( ពួកឥរិយាបថ ចប់)



Websites: WatKhemaraRatanaram.org or WatKhmers.org

# ៣- សម្បជញ្ញបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវ-កម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ៕**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) ជាអ្នកធ្វើកិច្ចទាំងគ្រប់ដោយប្រាជ្ញាដឹងសព្វក្នុងកិរិយាឈានចូល កិរិយាឈានថយ ធ្វើកិច្ចទាំងគ្រប់ ដោយប្រាជ្ញាដឹងសព្វក្នុងកិរិយាក្រឡេកមើលទៅមុខក្រឡេកមើលទៅទិសផ្សេងៗ ធ្វើកិច្ចទាំងគ្រប់ដោយប្រាជ្ញាដឹងសព្វកិរិយាបត់អង្គុញ លាត សណ្តូក (ដៃជើង) ធ្វើកិច្ចទាំងគ្រប់ដោយប្រាជ្ញាដឹងសព្វក្នុងកិរិយាទ្រទ្រង់នូវសង្ឃាដី និងបាត្រ និងចីវរ ធ្វើកិច្ចទាំងគ្រប់ដោយប្រាជ្ញាដឹងសព្វ ក្នុងកិរិយា ធ្វើនូវឧច្ចារៈ និងបស្សាវៈ ធ្វើកិច្ចទាំងគ្រប់ដោយប្រាជ្ញាដឹងសព្វក្នុងកិរិយាដើរ ឈរ អង្គុយ ដេក រលឹក និយាយស្ដីស្ងៀមនៅ ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ៗលៗ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណា ឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផងៗលៗ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផងៗ


Websites: WatKhemaraRatanaram.org or WatKhmers.org

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ៕**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ។

**“សម្បជញ្ញបព្វំ និដ្ឋិតំ”**

( ពួកសម្បជញ្ញៈ ចប់)

# ៤- បដិក្កូលបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ ៕**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) ពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើអំពីបាតជើងឡើងខាងក្រោមអំពីចុងសក់ចុះ ទីបំផុតជុំវិញអំពីត្រឹមស្បែកដែលពេញដោយវត្ថុមិនស្អាតមានប្រការផ្សេងៗដូច្នេះថា “មាននៅក្នុងកាយនេះសក់ទាំងឡាយ រោមទាំងឡាយ ក្រចកទាំងឡាយ ធ្មេញទាំងឡាយ ស្បែក សាច់ សរសៃទាំងឡាយ ឆ្អឹងទាំងឡាយ ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែកខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ” ។

**សេយ្យថាបិ ភិក្ខវេ ឧភតោមុខា មូតោឡី បូរា នានាវិហិតស្ស**


Websites: WatKhemaraRatanaram.org or WatKhmers.org

**ធញ្ញស្ស ខ សេយ្យថីទំ? សាលីនំ វីហីនំ មុគ្គានំ មាសានំ តិលានំ តណ្ឌុលានំ ខ តមេនំ ចក្ខុមា បុរិសោ មុញ្ចិត្វា បច្ចវេក្ខេយ្យ ឥមេ សាលី ឥមេ វីហី ឥមេ មុគ្គា ឥមេ មាសា ឥមេ តិលា ឥមេ តណ្ឌុលាតិ ៕**

ម្នាលភិក្ខុទាំងឡាយយ៉ាងដូចម្ដេចមិញថៃមានមុខទាំងសង ខាង ដែលពេលដោយធញ្ញជាតិមានប្រការផ្សេងៗ ។ ធញ្ញជាតិទាំងនេះគឺអ្វីខ្លះ ស្រូវសាលីទាំងឡាយ ស្រូវខ្សាយទាំងឡាយ សណ្ដែកបាយទាំងឡាយ សណ្ដែករាជមាសទាំងឡាយ ល្ងទាំងឡាយអង្ករទាំងឡាយ។ បុរសដែលមានចក្ខុបសាទ គប្បីស្រាយនូវថៃនោះហើយពិចារណាឃើញច្បាស់ដូច្នេះ ថា "នេះស្រូវសាលីទាំងឡាយ នេះសណ្ដែករាជមាសទាំងឡាយ នេះល្ង ទាំងឡាយនេះ អង្ករទាំងឡាយ"។

**ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា ខលខ លសិកាមុត្តន្តិ ៕**

ម្នាលភិក្ខុទាំងឡាយយ៉ាងដូច្នោះដែរ ភិក្ខុពិចារណាឃើញច្បាស់នូវ កាយនេះឯងខាងលើអំពីបាតជើងឡើងខាងក្រោម អំពីចុងសក់ចុះទីបំផុត ជុំវិញអំពីត្រឹមស្បែកដែលពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា "មាននៅក្នុងកាយនេះ សក់ទាំងឡាយ រោមទាំងឡាយ ។ល។ ទឹករំអិល ទឹកមូត្រ"។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ខលខ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិងទិដ្ឋិផង មិន ប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថាភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**“បដិក្កូលបព្វំ និដ្ឋិតំ”**

(ពួកបដិក្កូល ចប់)

# ៥- ធាតុបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។**

ម្នាលភិក្ខុទាំងឡាយនៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) ពិចារណាឃើញច្បាស់នូវកាយនេះឯងដែលស្ថិតនៅយ៉ាងណា ដែលតម្កល់នៅយ៉ាងណាដោយថាជាធាតុដូច្នេះថា "មាននៅក្នុងកាយនេះ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់"។

**សេយ្យថាបិ ភិក្ខវេ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា ចាតុម្មហាបថេ វិលសោ បដិវិភជិត្វា និសិន្នោអស្ស ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងដូចម្តេចមិញនាយគោឃាតដែលប៉ិនប្រសប់ក្តី កូនសិស្សនៃនាយគោឃាតក្តីគប្បីសម្លាប់នូវមេគោហើយរំលែកជាចំណែកៗ អង្គុយនៅទៀបផ្លូវធ្លាធំមានមុំ ៤ ។

**ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ**


Websites: WatKhemaraRatanaram.org or WatKhmers.org

**តេជោធាតុ វាយោធាតូតិ ៕**

ម្នាលភិក្ខុទាំងឡាយ យ៉ាងដូច្នោះដែរ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលស្ថិតនៅយ៉ាងណាដែលតម្កល់នៅយ៉ាងណា ដោយថាជាធាតុដូច្នេះថា "មាននៅក្នុងកាយនេះ ធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់" ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ៕ល៕ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ៕**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថាភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**"ធាតុបព្វំ និដ្ឋិតំ"**

(ពួកធាតុ ចប់)


Websites: WatKhemaraRatanaram.org or WatKhmers.org

# ៦- នវសីវថិកាបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វិនីលកំ វិបុព្វកជាតំ ៕**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) គប្បីឃើញនូវសេរីរៈស្លាប់យ៉ាងដូចម្តេចមិញ ដែលគេចោលនៅក្នុងព្រៃស្មសាន ទោះស្លាប់អស់ថ្ងៃ១ ក្តី ស្លាប់អស់ថ្ងៃ ២ ក្តី ស្លាប់អស់ថ្ងៃ ៣ក្តី ដែលកំពុងហើមមានពណ៌ខៀវ ដោយច្រើនមានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ**

ភិក្ខុនោះនាំចូលមកប្រៀបនូវកាយនេះឯងដូច្នេះថា "សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះគង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ" ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ៕ល៕ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ៕**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថាភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។


Websites: WatKhemaraRatanaram.org or WatKhmers.org

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ កាកេហិ វា ខជ្ជមានំ គិជ្ឈេហិ វា ខជ្ជមានំ កុលលេហិ វា ខជ្ជ-មានំ សុវានេហិ វា ខជ្ជមានំ សិង្គាលេហិ វា ខជ្ជមានំ វិវិធេហិ វា បាណកជាតេហិ ខជ្ជមានំ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) គប្បីឃើញនូវសរីរៈស្លាប់យ៉ាងដូចម្តេចមិញ ដែលគេចោលនៅក្នុងព្រៃស្មសាន ដែលក្អែកទាំងឡាយកំពុងចឹកស៊ីក្តី ដែលត្មាតទាំងឡាយកំពុងចឹកស៊ីក្តី ដែលត្រដក់ទាំងឡាយកំពុងចឹកស៊ីក្តី ដែលស្វានទាំងឡាយកំពុងកកេរស៊ីក្តី ដែលចចកទាំងឡាយកំពុងកកេរស៊ីក្តី ដែលបាណកជាតិទាំងឡាយមានប្រការផ្សេងៗ កំពុងរូងជញ្ជក់ស៊ីក្តី ។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ**

ភិក្ខុនោះនាំចូលមកប្រៀបនូវកាយនេះឯងដូច្នេះថា "សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះគង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ល។ អនិស្សិតោ ច វិហរតិ ន កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វីតិចតួច ក្នុងលោកផង។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ។**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិសង្ខលិកំ សមំសលោហិតំ ន្ហារុសម្ពន្ធំ ៚**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) គប្បីឃើញនូវសរីរៈ ស្លាប់យ៉ាងដូចម្តេចមិញ ដែលគេចោលនៅក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹង ប្រកបដោយសាច់និងឈាមនៅមានសរសៃជាគ្រឿងចង ។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ**

ភិក្ខុនោះនាំចូលមកប្រៀបនូវកាយនេះឯងដូច្នេះថា "សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះគង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ" ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ៚ល៚ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៚**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ៚**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិសង្ខលិកំ និម្មំសលោហិតមក្ខិតំ ន្ហារុសម្ពន្ធំ ៚**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) គប្បីឃើញនូវសរីរៈស្លាប់យ៉ាងដូចម្តេចមិញ ដែលគេចោលនៅក្នុងព្រៃ


Websites: WatKhemaraRatanaram.org or WatKhmers.org

ស្មសាន នៅសល់តែរាងឆ្អឹងឥតសាច់ នៅប្រឡាក់ដោយឈាមនៅមានសរសៃជាគ្រឿងចង ។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំអនតីតោតិ**

ភិក្ខុនោះនាំចូលមកប្រៀបនូវកាយនេះឯង ដូច្នេះថា "សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះគង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។ល។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ៕**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិសង្ខលិកំ អបគត មំសលោហិតំ ន្ហារុសម្ពន្ធំ ៕**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) គប្បីឃើញនូវសរីរៈស្លាប់យ៉ាងដូចម្តេចមិញ ដែលគេចោលនៅក្នុងព្រៃស្មសាននៅសល់តែរាងឆ្អឹង ឥតសាច់ ឥតឈាមនៅមានសរសៃជាគ្រឿងចង ។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំអនតីតោតិ ៕**


Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខុនោះនាំចូលមកប្រៀប នូវកាយនេះឯងដូច្នេះថា "សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះគង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។លៗ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ៕**

ម្នាល ភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗនូវកាយក្នុងកាយ ។

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ អបគត ន្ហារុសម្ពន្ធានិ ទិសាវិទិសាវិក្ខិត្តានិ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដិដ្ឋិកំ អញ្ញេន បិដ្ឋិកណ្ដកដ្ឋិកំ អញ្ញេន ផាសុកដ្ឋិកំ អញ្ញេន ឧរដ្ឋិកំ អញ្ញេន ពាហុដ្ឋិកំ អញ្ញេន អំសដ្ឋិកំ អញ្ញេន គីវដ្ឋិកំ អញ្ញេន ហនុដ្ឋិកំ អញ្ញេន ទន្តដ្ឋិកំ អញ្ញេន សីសកដាហំ ៕**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) ដែលគេចោលនៅក្នុងព្រៃស្មសាននៅសល់តែឆ្អឹងទទេ មានសរសៃជាគ្រឿងចងទៅប្រាសហើយខ្ចាត់ខ្ចាយរាត់រាយទៅក្នុងទិសតូចនិង ទិសធំផ្សេងៗ ឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងទ្រនុងខ្នងទៅដោយឡែក ឆ្អឹងជំនីទៅដោយឡែក ឆ្អឹងទ្រូងទៅដោយឡែក ឆ្អឹងដើមដៃ


Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅដោយឡែក ឆ្អឹងស្មាទៅដោយឡែក ឆ្អឹងកទៅដោយឡែក ឆ្អឹងចង្កា ទៅដោយឡែក ឆ្អឹងធ្មេញទៅដោយឡែក លលាដ៏ក្បាលទៅដោយឡែក។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ**

ភិក្ខុនោះនាំចូលមកប្រៀប នូវកាយនេះឯងដូច្នេះថា "សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះ គង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ"។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។បេ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ សេតានិ សង្ខវណ្ណូបនិភានិ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) គប្បីឃើញនូវសរីរៈស្លាប់យ៉ាងដូចម្ដេចមិញ ដែលគេចោលនៅក្នុងព្រៃស្មសាននៅសល់តែឆ្អឹងទទេមានពណ៌សប្រៀបដោយពណ៌នៃស័ង្ខ។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។**

ភិក្ខុនោះនាំចូលមកប្រៀបនូវកាយនេះឯង ដូច្នេះថា "សូម្បីកាយ


Websites: WatKhemaraRatanaram.org or WatKhmers.org

នេះសោត ក៏គង់នឹងមានសភាពដូច្នោះគង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ" ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។បេ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផល។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ៕**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហោថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ បុញ្ជកិតានិ តេរោវស្សិកានិ ៕**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) គប្បីឃើញនូវសេរីរៈស្លាប់យ៉ាងដូចម្ដេចមិញ ដែលគេចោលនៅក្នុងព្រៃស្មសាននៅសល់តែឆ្អឹងទទេ រោយរាយជាពំនូកៗ មានឆ្នាំមួយកន្លងហើយ ។

**សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ៕**

ភិក្ខុនោះនាំចូលមកប្រៀបនូវកាយនេះឯង ដូច្នេះថា "សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពដូច្នោះគង់នឹងក្លាយទៅជាដូច្នោះ នឹងកន្លងនូវភាពដូច្នោះពុំបានឡើយ ។

**ឥតិ អជ្ឈត្តំ វា កាយេ កាយានុបស្សី វិហរតិ ។បេ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**


Websites: WatKhemaraRatanaram.org or WatKhmers.org

ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង ។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ ។**

ម្នាលភិក្ខុទាំងឡាយ បែបនេះម្យ៉ាងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ ។

**“នវសីវថិកាបព្វំ និដ្ឋិតំ”**

(ពួកសីវថិកា អសុភ ៩ ចប់)

((កាយានុបស្សនាសតិបដ្ឋានំ និដ្ឋិតំ))

( កាយានុស្សនាសតិបដ្ឋាន ចប់ )



Websites: WatKhemaraRatanaram.org or WatKhmers.org

# វេទនានុបស្សនា

# សតិបដ្ឋាន

**កថញ្ច ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ?

**ឥធ ភិក្ខវេ ភិក្ខុ សុខំ វេទនំ វេទិយមានោ សុខំ វេទនំ វេទិយមានោ សុខំ វេទនំ វេទិយាមីតិ បជានាតិ ទុក្ខំ វេទនំ វេទិយមានោ ទុក្ខំ វេទនំ វេទិយាមីតិ បជានាតិ អទុក្ខមសុខំ វេទនំ វេទិយមានោ អទុក្ខមសុខំ វេទនំ វេទិយាមីតិ បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះសោយនូវវេទនាជាសុខដឹងច្បាស់ថា "អញសោយនូវវេទនាជាសុខ "ទោះសោយនូវវេទនាជាទុក្ខ ដឹងច្បាស់ថា "អញសោយនូវវេទនាជាទុក្ខ" ទោះសោយនូវវេទនាឥតទុក្ខ ឥតសុខ ដឹងច្បាស់ថា "អញសោយនូវវេទនាឥតទុក្ខ ឥតសុខ" ។

**សាមិសំ វា សុខំ វេទនំ វេទិយមានោ សាមិសំ សុខំ វេទនំ វេទិយាមីតិ បជានាតិ និរាមិសំ វា សុខំ វេទនំ វេទិយមានោ និរាមិសំ សុខំ វេទនំ វេទិយាមីតិ បជានាតិ ។**

ទោះសោយនូវវេទនាជាសុខ ដែលប្រកបដោយអាមិស ដឹងច្បាស់ថា "អញសោយនូវវេទនាជាសុខដែលប្រកបដោយអាមិស" ទោះសោយនូវវេទនាជាសុខដែលឥតអាមិស ដឹងច្បាស់ថា "អញសោយនូវវេទនាជាសុខដែលឥតអាមិស" ។


Websites: WatKhemaraRatanaram.org or WatKhmers.org

**សាមិសំ វា ទុក្ខំ វេទនំ វេទិយមានោ សាមិសំ ទុក្ខំ វេទនំ វេទិយាមីតិ បជានាតិ និរាមិសំ វា ទុក្ខំ វេទនំ វេទិយមានោ និរាមិសំ ទុក្ខំ វេទនំ វេទិយាមីតិ បជានាតិ ៕**

ទោះសោយនូវវេទនាជាទុក្ខ ដែលប្រកបដោយអាមិស ដឹងច្បាស់ថា "អញសោយនូវវេទនាជាទុក្ខដែលប្រកបដោយអាមិស "ទោះសោយនូវវេទនាជាទុក្ខដែលឥតអាមិស ដឹងច្បាស់ថា "អញសោយនូវវេទនាជាទុក្ខដែលឥតអាមិស" ។

**សាមិសំ វា អទុក្ខមសុខំ វេទនំ វេទិយមានោ សាមិសំ អទុក្ខម-សុខំ វេទនំ វេទិយាមីតិ បជានាតិ និរាមិសំ វា អទុក្ខសុខំ វេទនំ វេទិយមានោ និរាមិសំ អទុក្ខមសុខំ វេទនំ វេទិយាមីតិ បជានាតិ ៕**

ទោះសោយនូវវេទនា ឥតទុក្ខ ឥតសុខ ដែលប្រកបដោយអាមិស ដឹងច្បាស់ថា "អញសោយនូវវេទនាឥតទុក្ខ ឥតសុខ ដែលប្រកបដោយអាមិស" ទោះសោយនូវវេទនា ឥតទុក្ខ ឥតសុខ ដែលឥតអាមិស ដឹងច្បាស់ថា "អញសោយនូវវេទនា ឥតទុក្ខ ឥតសុខ ដែលឥតអាមិស" ។

**ឥតិ អជ្ឈត្តំ វា វេទនាសុ វេទនានុបស្សី វិហរតិ ពហិទ្ធា វា វេទនាសុ វេទនានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា វេទនាសុ វេទនា-នុបស្សី វិហរតិ សមុទយធម្មានុបស្សី វា វេទនាសុ វិហរតិ វយធម្មា-នុបស្សី វា វេទនាសុ វិហរតិ សមុទយវយធម្មានុបស្សី វា វេទនាសុ វិហរតិ អត្ថិ វេទនាតិ វា បន ស្សសតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនា


Websites: WatKhemaraRatanaram.org or WatKhmers.org

ទាំងឡាយជាខាងក្រៅ (របស់អ្នកដទៃ) ផង ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅផង ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងវេទនាទាំងឡាយផង ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយផង។ ម្យ៉ាងទៀតស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា "គ្រាន់តែជាវេទនាទាំងឡាយ" (មិនមែនសត្វមិនមែនបុគ្គលមិនមែនស្ត្រី មិនបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវំ ខោ ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ ៗ**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗនូវវេទនាទាំងឡាយ ។

**"វេទនានុបស្សនាសតិបដ្ឋានំ និដ្ឋិតំ"**

(វេទនានុបស្សនាសតិបដ្ឋាន ចប់)


Websites: WatKhemaraRatanaram.org or WatKhmers.org

# ចិត្តានុបស្សនា

# សតិបដ្ឋាន

**កថញ្ច ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចភិក្ខុពិចារណាឃើញរឿយៗនូវចិត្តក្នុងចិត្ត ?

**ឥធ ភិក្ខវេ ភិក្ខុ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះចិត្តប្រកបដោយរាគៈ ដឹងច្បាស់ថា "ចិត្តប្រកបដោយរាគៈ" ទោះចិត្តប្រាសចាករាគៈ ដឹងច្បាស់ថា "ចិត្តប្រាសចាករាគៈ" ។

**សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ ។**

ទោះចិត្តប្រកបដោយទោសៈ ដឹងច្បាស់ថា "ចិត្តប្រកបដោយទោសៈ" ទោះចិត្តប្រាសចាកទោសៈដឹងច្បាស់ថា "ចិត្តប្រាសចាកទោសៈ" ។

**សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ ។**

ទោះចិត្តប្រកបដោយមោហៈ ដឹងច្បាស់ថា "ចិត្តប្រកបដោយមោហៈ" ទោះចិត្តប្រាសចាកមោហៈ ដឹងច្បាស់ថា "ចិត្តប្រាសចាកមោហៈ" ។


Websites: WatKhemaraRatanaram.org or WatKhmers.org

**សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ ។**

**សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ ៚**

ទោះចិត្តរួញរា ដឹងច្បាស់ថា "ចិត្តរួញរា" ទោះចិត្តរាយមាយដឹងច្បាស់ថា "ចិត្តរាយមាយ" ។

**មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ ៚**

ទោះចិត្តដល់នូវភាវៈជាធំ ដឹងច្បាស់ថា "ចិត្តដល់នូវភាវៈជាធំ" ទោះចិត្តមិនដល់នូវភាវៈជាធំ ដឹងច្បាស់ថា "ចិត្តមិនដល់នូវភាវៈជាធំ" ។

**សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ ៚**

ទោះចិត្តដល់នូវភាវៈជាធំ ដឹងច្បាស់ថា "ចិត្តនៅមានចិត្តដទៃប្រសើរជាង" ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង ដឹងច្បាស់ថា "ចិត្តមិនមានចិត្តដទៃប្រសើរជាង" ។

**សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ ៚**

ទោះចិត្តតម្កល់នៅមាំដឹងច្បាស់ថា "ចិត្តតម្កល់នៅមាំ" ទោះចិត្តមិនតម្កល់នៅមាំ ដឹងច្បាស់ថា "ចិត្តមិនតម្កល់នៅមាំ" ។

**វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ៚**

ទោះចិត្តផុតស្រឡះ ដឹងច្បាស់ថា "ចិត្តផុតស្រឡះ" ទោះចិត្តមិនផុតស្រឡះ ដឹងច្បាស់ថា "ចិត្តមិនផុតស្រឡះ" ។

**ឥតិ អជ្ឈត្តំ វា ចិត្តេ ចិត្តានុបស្សី វិហរតិ ពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ចិត្តេ ចិត្តានុបស្សី វិហរតិ សមុទយ-**


Websites: WatKhemaraRatanaram.org or WatKhmers.org

**ធម្មានុបស្សី វា ចិត្តស្មឹ វិហរតិវយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ សមុទយវយធម្មានុបស្សី វា ចិត្តស្មឹ វិហរតិ ។ អត្ថិ ចិត្តន្តិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្នុង(របស់ខ្លួន) ដូច្នេះផង ពិចារណាឃើញរឿយៗនូវចិត្តក្នុងចិត្តជាខាងក្រៅ (របស់អ្នកដទៃ) ផង ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តទាំងខាងក្នុង ទាំងខាងក្រៅផង ពិចារណាឃើញរឿងៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងចិត្តផង ពិចារណាឃើញរឿយៗនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងចិត្តផង ម្យ៉ាងទៀតស្មារតីរបស់ភិក្ខុនោះ ក៏ផ្ចង់ឡើងចំពោះថា គ្រាន់តែជាចិត្ត (មិនមែនសត្វ មិនមែនបុគ្គលមិនមែនស្ត្រី និងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវំ ខោ ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត ។

**“ចិត្តានុបស្សនាសតិបដ្ឋានំ និដ្ឋិតំ”**

(ចិត្តានុបស្សនាសតិបដ្ឋាន ចប់)


Websites: WatKhemaraRatanaram.org or WatKhmers.org

# ធម្មានុបស្សនា
# សតិបដ្ឋាន

((មាន ៥ បព្វៈ))

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ?

## ១- នីវរណបព្វ

**ឥធ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ៕**

ម្នាលភិក្ខុទាំងឡាយភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ នីវរណៈ ៥ ។

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ នីវរណេសុ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ នីវរណៈ ៥ ?

**ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ**


Websites: WatKhemaraRatanaram.org or WatKhmers.org

**តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈមាននៅក្នុងខ្លួន ដឹងច្បាស់ថា "កាមច្ឆន្ទៈមាននៅក្នុងខ្លួនរបស់អញ" ទោះកាមច្ឆន្ទៈមិនមាននៅក្នុងខ្លួនដឹងច្បាស់ថា "កាមច្ឆន្ទៈមិនមាននៅក្នុងខ្លួនរបស់អញ" ម្យ៉ាងទៀត កិរិយាកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវកាមច្ឆន្ទៈដែលកើតឡើងហើយដោយហេតុឯណាក៏ដឹង ច្បាស់នូវហេតុនោះផងកិរិយាមិនកើតតទៅទៀតនៃកាមច្ឆន្ទៈ ដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**សន្តំ វា អជ្ឈត្តំ ព្យាបាទំ អត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ នត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ យថា ច អនុប្បន្នស្ស ព្យាបាទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ព្យាបាទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ព្យាបាទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។**

ទោះព្យាបាទមាននៅក្នុងខ្លួន ដឹងច្បាស់ថា "ព្យាបាទមាននៅក្នុងខ្លួនរបស់អញ" ទោះព្យាបាទមិនមាននៅក្នុងខ្លួន ដឹងច្បាស់ថា "ព្យាបាទមិនមាននៅក្នុងខ្លួនរបស់អញ" ម្យ៉ាងទៀត កិរិយាកើតឡើងនៃព្យាបាទដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវព្យាបាទ ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតទៅទៀតនៃព្យាបាទ ដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ**


Websites: WatKhemaraRatanaram.org or WatKhmers.org

**អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ យថា ច អនុប្បន្នស្ស ថីនមិទ្ធស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ថីនមិទ្ធស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ថីនមិទ្ធស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។**

ទោះថីនមិទ្ធៈមាននៅក្នុងខ្លួន ដឹងច្បាស់ថ "ថីនមិទ្ធៈមាននៅក្នុងខ្លួនរបស់អញ" ទោះថីនមិទ្ធៈមិនមាននៅក្នុងខ្លួន ដឹងច្បាស់ថា "ថីនមិទ្ធៈមិនមាននៅក្នុងខ្លួនរបស់អញ" ម្យ៉ាងទៀត កិរិយាកើតឡើងនៃថីនមិទ្ធៈដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវថីនមិទ្ធៈ ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផងកិរិយាមិនកើតតទៅទៀតនៃថីនមិទ្ធៈ ដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**សន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។**

ទោះវិចិកិច្ឆាមាននៅក្នុងខ្លួន ដឹងច្បាស់ថា "វិចិកិច្ឆា មាននៅក្នុងខ្លួនរបស់អញ" ទោះវិចិកិច្ឆាមិនមាននៅក្នុងខ្លួន ដឹងច្បាស់ថា "វិចិកិច្ឆាមិនមាននៅក្នុងខ្លួនរបស់អញ" ម្យ៉ាងទៀត កិរិយាកើតឡើងនៃវិចិកិច្ឆាដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវវិចិកិច្ឆា ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ កិរិយាមិនកើតតទៅទៀតនៃវិចិកិច្ឆាដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។


Websites: WatKhemaraRatanaram.org or WatKhmers.org

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយខាងក្រៅ(របស់អ្នកដទៃ) ផង ពិចារណាឃើញរឿយៗនូវធម៌ក្នុងធម៌ទាំងឡាយ ទាំងខាងក្នុង ទាំងខាងក្រៅផងពិចារណា ឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងធម៌ទាំងឡាយផងពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយផង ពិចារណាឃើញរឿយៗនូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយផង ។ម្យ៉ាងទៀតស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា "គ្រាន់តែជាធម៌ទាំងឡាយ (មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី និងបុរសជាដើម) ល្មមតែកំណត់ ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង ។មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និងទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុធម្មានុបស្សី វិហរតិ បញ្ចសុ និវរណេសុ ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺនីវរណៈ ៥ ។

**"នីវរណបព្វំ និដ្ឋិតំ"**

(ពួកនីវរណៈ ចប់)


Websites: WatKhemaraRatanaram.org or WatKhmers.org

# ២- ខន្ធបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ៕**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ ឧបាទានក្ខន្ធ ៥ ។

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ?**

ម្នាលភិក្ខុទាំងឡាយ "ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធ ៥" ?

**ឥធ ភិក្ខវេ ភិក្ខុ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ វេទនាយ សមុទយោ ឥតិ វេទនាយ អត្ថង្គមោ ឥតិ សញ្ញា ឥតិ សញ្ញាយ សមុទយោ ឥតិ សញ្ញាយ អត្ថង្គមោ ឥតិ សង្ខារា ឥតិ សង្ខារានំ សមុទយោ ឥតិ សង្ខារានំ អត្ថង្គមោ ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ ៕**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ (ដឹងច្បាស់ដូច្នេះថា)រូបមានប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃរូបមានប៉ុណ្ណេះ វេទនាមានប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃវេទនាមានប៉ុណ្ណេះ សញ្ញាមានប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើងនៃសញ្ញាមានប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃសញ្ញាមានប៉ុណ្ណេះ សង្ខារទាំងឡាយមានប៉ុណ្ណេះ ធម៌ដែលជាដែនកើតឡើង នៃសង្ខារទាំងឡាយមានប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃសង្ខារទាំងឡាយមានប៉ុណ្ណេះ វិញ្ញាណមានប៉ុណ្ណេះធម៌ដែលជា


Websites: WatKhemaraRatanaram.org or WatKhmers.org

ដែនកើតឡើងនៃវិញ្ញាណមានប៉ុណ្ណេះ ធម៌ដែលជាដែនរលត់ទៅនៃវិញ្ញាណមានប៉ុណ្ណេះ ។

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ។បេ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ បញ្ចសុ ឧបាទានក្ខន្ធេសុ ៕**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺឧបាទានក្ខន្ធ៥ ។

**“ខន្ធបព្វំ និដ្ឋិតំ”**

(ពួកខន្ធ ចប់)


Websites: WatKhemaraRatanaram.org or WatKhmers.org

# ៣- អាយតនបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិក-ពាហិរេសុ អាយតនេសុ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ។

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិក-ពាហិរេសុ អាយតនេសុ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ?

**ឥធ ភិក្ខវេ ភិក្ខុ ចក្ខុញ្ច បជានាតិ រូបេច បជានាតិ យញ្ច តទុភយំ បដិច្ច ឧប្បជ្ជតិ សញ្ញោជនំ តញ្ច បជានាតិ យថា ច អនុប្បន្នស្ស សញ្ញោជនស្ស ឧប្បាទោ ហោតិ តញ្ច បជានា តិយថា ច ឧប្បន្នស្ស សញ្ញោជនស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស សញ្ញោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់នូវចក្ខុផង ដឹងច្បាស់នូវរូបារម្មណ៍ទាំងឡាយផងម្យ៉ាងទៀត សញ្ញោជនៈឯណាដែលអាស្រ័យនូវចក្ខុ និងរូបារម្មណ៍ទាំងពីរនោះ ហើយកើតឡើងក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង កិរិយាកើតឡើងនៃសញ្ញោជនៈដែលមិនទាន់កើតឡើងដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាលះបង់នូវសញ្ញោជនៈ ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀត នៃសញ្ញោជនៈដែលលះបង់បាន


Websites: WatKhemaraRatanaram.org or WatKhmers.org

ហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀត នៃសញ្ញោជនៈដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**សោតញ្ច បជានាតិ សទ្ទេ ច បជានាតិ**........

ដឹងច្បាស់នូវសោតៈផងដឹងច្បាស់នូវសទ្ទារម្មណ៍ទាំងឡាយផង...

**ឃានញ្ច បជានាតិ គន្ធេ ច បជានាតិ**.......

ដឹងច្បាស់នូវឃានៈផង. ដឹងច្បាស់នូវគន្ធារម្មណ៍ទាំងឡាយផង...

**ជិវ្ហញ្ច បជានាតិ រសេ ច បជានាតិ**......

ដឹងច្បាស់នូវជីវ្ហាផង. ដឹងច្បាស់នូវសោរម្មណ៍ទាំងឡាយផង...

**កាយញ្ច បជានាតិ ផោដ្ឋព្វេ ច បជានាតិ**.....

ដឹងច្បាស់នូវកាយផង. ដឹងច្បាស់នូវផោដ្ឋព្វារម្មណ៍ទាំងឡាយផង..

**មនញ្ច បជានាតិ ធម្មេ ច បជានាតិ យញ្ច តទុភយំ បដិច្ចឧប្បជ្ជតិ សញ្ញោជនំ តញ្ចបជានាតិ ៗលៗ យថា ច បហីនស្ស សញ្ញោជនស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ៗ**

ដឹងច្បាស់នូវមនោផង ដឹងច្បាស់នូវធម្មារម្មណ៍ទាំងឡាយផង ម្យ៉ាងទៀត សញ្ញោជនៈ ឯណាដែលអាស្រ័យនូវមនោ និង ធម្មារម្មណ៍ទាំងពីរនោះហើយកើតឡើង ក៏ដឹងច្បាស់នូវសញ្ញោជនៈនោះផង។ល។ កិរិយាមិនកើត តទៅទៀតនៃសញ្ញោជនៈដែលលះបង់បានហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ៗលៗ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ៗ**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និង


Websites: WatKhemaraRatanaram.org or WatKhmers.org

ទិដ្ឋិផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយគឺអាយតនៈ ៦ ទាំងខាងក្នុង ទាំងខាងក្រៅ ។

**"អាយតនបព្វំ និដ្ឋិតំ"**

(ពួកអាយតនៈ ចប់)

# ៤- ពោជ្ឈង្គបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុ(ក្នុងសាសនានេះ) ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គៈ ៧ ។

**ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ សតិសម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ សតិសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស សតិសម្ពោ-ជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស សតិសម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ ហោតិ តញ្ច បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះសតិសម្ពោជ្ឈង្គៈ


Websites: WatKhemaraRatanaram.org or WatKhmers.org

មាននៅក្នុងខ្លួន ដឹងច្បាស់ថា "សតិសម្ពោជ្ឈង្គៈ មាននៅក្នុងខ្លួនរបស់អញ" ទោះសតិសម្ពោជ្ឈង្គៈ មិនមាននៅក្នុងខ្លួនដឹងច្បាស់ថា "សតិសម្ពោជ្ឈង្គៈមិនមាននៅក្នុងខ្លួនរបស់អញ" ម្យ៉ាងទៀតកិរិយាកើតឡើងនៃសតិសម្ពោជ្ឈង្គៈ ដែលមិនទាន់កើតឡើង ដោយហេតុឯណាក៏ដឹងច្បាស់នូវហេតុនោះផងកិរិយាចម្រើនពេញបរិបូណ៌នៃសតិសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**សន្តំ វា អជ្ឈត្តំ ធម្មវិចយសម្ពោជ្ឈង្គំ...**

ទោះធម្មវិចយសម្ពោជ្ឈង្គៈមាននៅក្នុងខ្លួន...

**សន្តំ វា អជ្ឈត្តំ វិរិយសម្ពោជ្ឈង្គំ...**

ទោះវិរិយសម្ពោជ្ឈង្គៈមាននៅក្នុងខ្លួន...

**សន្តំ វា អជ្ឈត្តំ បីតិសម្ពោជ្ឈង្គំ...**

ទោះ បីតិសម្ពោជ្ឈង្គៈ មាននៅក្នុងខ្លួន...

**សន្តំ វា អជ្ឈត្តំ បស្សទ្ធិសម្ពោជ្ឈង្គំ...**

ទោះបស្សទ្ធិសម្ពោជ្ឈង្គៈមាននៅក្នុងខ្លួន...

**សន្តំ វា អជ្ឈត្តំ សមាធិសម្ពោជ្ឈង្គំ...**

ទោះសមាធិសម្ពោជ្ឈង្គៈមាននៅក្នុងខ្លួន...

**សន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ អត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោ-តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គំ នត្ថិ មេ អជ្ឈត្តំ ឧបេក្ខាសម្ពោជ្ឈង្គោតិ បជានាតិ យថា ច អនុប្បន្នស្ស ឧបេក្ខាសម្ពោ-ជ្ឈង្គស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧបេក្ខា-សម្ពោជ្ឈង្គស្ស ភាវនាបារិបូរិ ហោតិ តញ្ច បជា នាតិ ។**

ទោះឧបេក្ខាសម្ពោជ្ឈង្គៈ មាននៅក្នុងខ្លួនដឹងច្បាស់ថា "ឧបេក្ខាសម្ពោជ្ឈង្គៈមាននៅក្នុងខ្លួនរបស់អញ "ទោះឧបេក្ខាម្ពោជ្ឈង្គៈ មិនមាន

នៅក្នុងខ្លួនរបស់អញ” ម្យ៉ាងទៀត កិរិយាកើតឡើងនៃ ឧបេក្ខាសម្ពោជ្ឈង្គៈ ដែលមិនទាន់កើតឡើងដោយហេតុឯណាក៏ដឹងច្បាស់នូវហេតុនោះ ផង កិរិយាចម្រើនពេញបរិបូណ៌នៃឧបេក្ខាសម្ពោជ្ឈង្គៈ ដែលកើតឡើងហើយ ដោយហេតុឯណា ក៏ដឹងច្បាស់នូវហេតុនោះផង ។

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ។បេ។ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ ។**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផង ។ល។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហា និង ទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ សត្តសុ ពោជ្ឈង្គេសុ ។**

ម្នាលភិក្ខុទាំងឡាយយ៉ាងនេះឯង ហៅថាភិក្ខុពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គៈ ៧។

**“ពោជ្ឈង្គបព្វំ និដ្ឋិតំ”**

(ពួកពោជ្ឈង្គៈ ចប់)

**“បឋមភាណវារោ”**

(បឋមភាណវារៈ ចប់)



Websites: WatKhemaraRatanaram.org or WatKhmers.org

# ៥-សច្ចបព្វ

**បុន ចបរំ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ។**

ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចៈ ៤។

**កថញ្ច ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺអរិយសច្ចៈ ៤ ?

**ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុ(ក្នុងសាសនានេះ) ដឹងច្បាស់តាមពិត ដូច្នេះថា "នេះទុក្ខ" ដឹងច្បាស់តាមពិត ដូច្នេះថា "នេះធម៌ជាដែនកើតឡើងនៃទុក្ខ" ដឹងច្បាស់តាមពិតដូច្នេះថា "នេះធម៌ជាទីរលត់ទៅនៃទុក្ខ" ដឹងច្បាស់តាមពិតដូច្នេះថា "នេះដំណើរទៅកាន់ធម៌ជាទីរលត់ទៅនៃទុក្ខ" ។

## ទុក្ខសច្ច

**កតមញ្ច ភិក្ខវេ ទុក្ខំអរិយសច្ចំ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា? "ទុក្ខអរិយសច្ចៈ"?


Websites: WatKhemaraRatanaram.org or WatKhmers.org

**ជាតិបិ ទុក្ខា ជរាបិ ទុក្ខា មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោ-មនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ។**

កំណើត ចាត់ថាជាទុក្ខ១ សេចក្តីចាស់ចាត់ថា ជាទុក្ខ១ សេចក្តីស្លាប់ ចាត់ថាជាទុក្ខ១ សេចក្តីសោក ចាត់ថាជាទុក្ខ១ សេចក្តីខ្សឹកខ្សួល ចាត់ថាជាទុក្ខ១ សេចក្តីលំបាកកាយ ចាត់ថាជាទុក្ខ១ សេចក្តីអាក់អន់ចិត្ត ចាត់ថាជាទុក្ខ១ សេចក្តីខ្លោចផ្សាចិត្តចាត់ថាជាទុក្ខ១ កិរិយាជួបប្រសព្វដោយទុក្ខ១ កិរិយាព្រាត់ប្រាស ចាកសត្វ និងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ចាត់ថាជាទុក្ខ១ ប្រាថ្នានូវហេតុឯណាមិនបាននូវហេតុនោះ ចាត់ថាជាទុក្ខ១ ដោយបង្រួមមកឧបាទានក្ខន្ធទាំងឡាយ៥ ចាត់ថាជាទុក្ខ១ ។

**កតមា ច ភិក្ខវេ ជាតិ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "កំណើត" ?

**យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជាតិ សញ្ជាតិ ឱក្កន្តិ និព្វត្តិ អភិនិព្វត្តិ ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ អយំ វុច្ចតិ ភិក្ខវេ ជាតិ ។**

កិរិយាកកើតឯណា កិរិយាកើតព្រមឯណា កិរិយាយាងចុះកាន់គតិឯណា កិរិយាប្រព្រឹត្តទៅមិនដាច់ឯណាកិរិយាកើតប្រាកដ នៃខន្ធទាំងឡាយឯណា កិរិយាបានចំពោះនូវអាយតនៈទាំងឡាយណា នៃសត្វទាំងឡាយនោះៗ ក្នុងពួកនៃសត្វនោះៗ ម្នាលភិក្ខុទាំងឡាយនេះតថាគតចាត់ឲ្យឈ្មោះថា "កំណើត" ។

**កតមា ច ភិក្ខវេ ជរា** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា "សេចក្ដីចាស់" ?

**យា តេសំ តេសំ សត្តានំ តម្ហិ តម្ហិ សត្តនិកាយេ ជរា ជីរណតា ខណ្ឌិច្ចំ បលិតចតា វលិតចតា អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ អយំ វុច្ចតិ ភិក្ខវេ ជរា ៕**

សេចក្ដីគ្រាំគ្រាឯណា ភាពដែលគ្រាំគ្រាឯណា ភាពដែលធ្មេញបាក់ឯណា កិរិយាថយទៅនៃអាយុឯណា កិរិយាទ្រោមទៅនៃឥន្ទ្រិយ ទាំងឡាយឯណា នៃសត្វទាំងឡាយនោះៗ ក្នុងពួកនៃសត្វ នោះៗ ម្នាលភិក្ខុទាំងឡាយនេះតថាគតចាត់ឲ្យឈ្មោះថា "សេចក្ដីចាស់" ។

**កតមញ្ច ភិក្ខវេ មរណំ** ?

ម្នាល ភិក្ខុទាំងឡាយដូចម្ដេចហៅថា "សេចក្ដីស្លាប់" ?

**យា តេសំ តេសំ សត្តានំ តម្ហា តម្ហា សត្តនិកាយា ចុតិ ចវនតា ភេទោ អន្តរធានំ មច្ចុមរណំ កាលកិរិយា ខន្ធានំ ភេទោ កឡេវរស្ស និក្ខេបោ ជីវិតិន្ទ្រិយស្ស ឧបច្ឆេទោ ឥទំ វុច្ចតិ ភិក្ខវេ មរណំ ៕**

កិរិយាឃ្លាតទៅឯណា ភាពនៃកិរិយាឃ្លាតទៅឯណាកិរិយាបែកធ្លាយទៅឯណា កិរិយាបាត់បង់ទៅឯណា សេចក្ដីស្លាប់ដោយមច្ចុឯណា កិរិយាធ្វើនូវមរណកាលឯណា កិរិយាបែកធ្លាយនៃខន្ធទាំងឡាយឯណា កិរិយាដាក់ចុះនូវអត្តភាពឯណា កិរិយាផ្ដាច់បង់នូវ ជីវិតិន្ទ្រិយឯណា នៃសត្វទាំងឡាយនោះៗ ចាកពួកនៃសត្វនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "សេចក្ដីស្លាប់" ។

**កតមោ ច ភិក្ខវេ សោកោ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា "សេចក្ដីសោក" ?

**យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស សោកោ សោចនា សោចិតត្តំ**


Websites: WatKhemaraRatanaram.org or WatKhmers.org

**អញ្ញោ បរិសោកោ អយំ វុច្ចតិ ភិក្ខវេ សោកោ ។**

ម្នាលភិក្ខុទាំងឡាយ សេចក្តីសោកស្តាយឯណាសេចក្តីស្រងេះស្រងោចឯណា ភាពដែលសោកស្តាយឯណាសេចក្តីរីងស្ងួតក្នុងចិត្តឯណា សេចក្តីក្រៀមក្រំក្នុងចិត្តឯណានៃសត្វដែលប្រកបហើយ ដោយសេចក្តីវិនាសណាមួយដែលហេតុនៃសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយនេះតថាគត ចាត់ឲ្យឈ្មោះថា "សេចក្តីសោក" ។

**កតមោ ច ភិក្ខវេ បរិទេវោ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីខ្សឹកខ្សួល" ?

**យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខធម្មេន ផុដ្ឋស្ស អាទេវោ បរិទេវោ អាទេវនា បរិទេវនា អាទេវិតត្តំ បរិទេវិតត្តំ អយំ វុច្ចតិ ភិក្ខវេ បរិទេវោ ។**

ម្នាលភិក្ខុទាំងឡាយ សភាពដែលទួញរកឯណាសភាពដែលទួញរៀបរាប់ឯណា កិរិយាទ្រូកឯណា កិរិយាទួញរៀបរាប់ឯណា ភាពដែលដែលទួញរកឯណា ភាពដែលទួញរៀបរាប់ឯណា នៃសត្វដែលប្រកបហើយ ដោយសេចក្តីវិនាសណាមួយ ដែលហេតុនៃសេចក្តីទុក្ខណាមួយពាលត្រូវហើយ ម្នាលភិក្ខុទាំងឡាយ តថាគត ចាត់ឲ្យឈ្មោះថា "សេចក្តីខ្សឹកខ្សួល" ។

**កតមញ្ច ភិក្ខវេ ទុក្ខំ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីលំបាកកាយ" ?

**យំ ខោ ភិក្ខវេ កាយិកំ ទុក្ខំ កាយិកំ អសាតំ កាយសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ ។**

ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកប្រព្រឹត្តទៅក្នុងកាយឯណា សេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងកាយឯណាកិរិយាសោយអារម្មណ៍ ជា


Websites: WatKhemaraRatanaram.org or WatKhmers.org

ទុក្ខ មិនជាទីត្រេកអរដែលកើតអំពីកាយសម្ផស្សឯណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "សេចក្តីលំបាកកាយ" ។

**កតមញ្ច ភិក្ខវេ ទោមនស្សំ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីអាក់អន់ចិត្ត" ?

**យំ ខោ ភិក្ខវេ ចេតសិកំ ទុក្ខំ ចេតសិកំ អសាតំ ចេតោសម្ផស្សជំ ទុក្ខំ អសាតំ វេទយិតំ ឥទំ វុច្ចតិ ភិក្ខវេ ទោមនស្សំ ។**

ម្នាលភិក្ខុទាំងឡាយ សេចក្តីលំបាកប្រព្រឹត្តទៅក្នុងចិត្តឯណាសេចក្តីមិនត្រេកអរប្រព្រឹត្តទៅក្នុងចិត្តឯណា កិរិយាសោយអារម្មណ៍ជាទុក្ខ មិនជាទីត្រេកអរ ដែលកើតអំពីចិត្តសម្ផស្សឯណា ម្នាលភិក្ខុទាំងឡាយនេះតថាគតចាត់ឲ្យឈ្មោះថា "សេចក្តីអាក់អន់ចិត្ត" ។

**កតមោ ច ភិក្ខវេ ឧបាយាសោ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីខ្លោចផ្សាចិត្ត" ?

**យោ ខោ ភិក្ខវេ អញ្ញតរញ្ញតរេន ព្យសនេន សមន្នាគតស្ស អញ្ញតរញ្ញតរេន ទុក្ខ ធម្មេន ផុដ្ឋស្ស អាយាសោ ឧបាយាសោ អាយាសិតត្តំ ឧបាយាសិតត្តំ អយំ វុច្ចតិ ភិក្ខវេ ឧបាយាសោ**

ម្នាលភិក្ខុទាំងឡាយ សេចក្តីតានតឹងក្នុងចិត្តឯណាសេចក្តីខ្លោចផ្សាក្នុងចិត្តឯណា ភាពដែលតានតឹងក្នុងចិត្តឯណាភាពដែលខ្លោចផ្សាក្នុងចិត្តឯណា នៃសត្វដែលប្រកបហើយដោយសេចក្តីវិនាសណាមួយ ដែលហេតុនៃសេចក្តីទុក្ខណាមួយពាល់ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "សេចក្តីខ្លោចផ្សាចិត្ត" ។

**កតមោ ច ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ?**

ម្នល ភិក្ខុទាំងឡាយ ដូចម្តេចហៅថា "កិរិយាជួបប្រសព្វដោយសត្វនិងសង្ខារទាំងឡាយមិនជាទីស្រឡាញ់ជាទុក្ខ" ?


Websites: WatKhemaraRatanaram.org or WatKhmers.org

**ឥធ ភិក្ខវេ យស្ស តេ ហោន្តិ អនិដ្ឋា អកន្តា អមនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អនត្ថកាមា អហិតកាមា អផាសុកាមា អយោគក្ខេមកាមា យាតេហិ សំគតិ សមាគមោ សមោធានំ មិស្សីភាវោ អយំ វុច្ចតិ ភិក្ខវេ អប្បិយេហិ សម្បយោគោ ទុក្ខោ ។**

ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ ទាំងឡាយឯណា ក្នុងលោកនេះ ដែលមិនជាទីប្រាថ្នា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត ពុំនោះសោត ជនទាំងឡាយឯណា ដែលមានប្រាថ្នានូវកម្មមិនចម្រើន មានប្រាថ្នានូវកម្មមិនជាប្រយោជន៍ មានប្រាថ្នានូវកម្ម ដែលមិនក្សេមចាកយោគៈ កិរិយាដើររួមគ្នាឯណា កិរិយាមកជួបគ្នាឯណា កិរិយាប្រជុំគ្នាឯណា ភាពជាអ្នកច្រឡូកច្រឡំគ្នា ឯណា ដោយអារម្មណ៍ទាំងឡាយនោះៗ ដោយជនទាំងឡាយនោះៗម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "កិរិយាជួបប្រសព្វដោយសត្វនិងសង្ខារទាំងឡាយមិនជាទីស្រឡាញ់ជាទុក្ខ" ។

**កតមោ ច ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ ?**

ម្នាលភិក្ខុទាំងឡាយដូចម្តេចហៅថា "កិរិយាព្រាត់ប្រាសចាកសត្វនិងសង្ខារទាំងឡាយជាទីស្រឡាញ់ជាទុក្ខ" ?

**ឥធ ភិក្ខវេ យស្ស តេ ហោន្តិ ឥដ្ឋា កន្តា មនាបា រូបា សទ្ទា គន្ធា រសា ផោដ្ឋព្វា យេ វា បនស្ស តេ ហោន្តិ អត្ថកាមា ហិតកាមា ផាសុកាមា យោគក្ខេមកាមា មាតា វា បិតា វា ភាតាវា ភគិនី វា មិត្តា វា អមច្ចា វា ញាតិលោហិតា វា យា តេហិ អសំគតិ អសមាគមោ អសមោធានំ អមិស្សីភាវោ អយំ វុច្ចតិ ភិក្ខវេ បិយេហិ វិប្បយោគោ ទុក្ខោ ។**

ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសារម្មណ៍ ផោដ្ឋព្វារម្មណ៍ទាំងឡាយឯណាក្នុងលោកនេះ ដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្តពុំនោះសោត ជនទាំងឡាយឯណា ដែលមានប្រាថ្នានូវកម្មដែលចម្រើន មានប្រាថ្នានូវកម្មជាប្រយោជន៍ មានប្រាថ្នានូវកម្មជាទីសប្បាយ មានប្រាថ្នានូវកម្មដែលក្សេមចាកយោគៈទោះមាតាក្តី បិតាក្តី បងប្អូនប្រុសក្តី បងប្អូនស្រីក្តី មិត្តក្តី អាមាត្យក្តី ញាតិសាលោហិតក្តី កិរិយាមិនបានដើររួមគ្នាឯណា កិរិយាមិនបានមកជួបគ្នាឯណា កិរិយាមិនបានប្រជុំគ្នាឯណា ភាពជាអ្នកមិនបានច្រឡូកច្រឡំគ្នាឯណា ដោយអារម្មណ៍ទាំងឡាយនោះៗ ដោយជនទាំងឡាយនោះៗ ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "កិរិយាព្រាត់ប្រាសចាកសត្វ និងសង្ខារទាំងឡាយជាទីស្រឡាញ់ជាទុក្ខ" ។

**កតមញ្ច ភិក្ខវេ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "ប្រាថ្នានូវហេតុឯណាមិនបាននូវហេតុនោះ ជាទុក្ខ" ?

**ជាតិធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន ជាតិធម្មា អស្សាម ន ច វត នោ ជាតិ អាគច្ឆេយ្យាតិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ៕**

ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាកើតឡើងដល់សត្វទាំងឡាយ ដែលមានកំណើតជាធម្មតាយ៉ាងនេះថា "អើហ្ន៎! សូមឲ្យយើងទាំងឡាយ កុំគប្បីជាអ្នកមានកំណើតជាធម្មតាពុំនោះសោតកំណើត កុំគប្បីជាអ្នកមកដល់យើងទាំងឡាយ" ហើយហេតុនោះក៏សត្វទាំងឡាយ មិនគប្បីដល់តាមសេចក្តីប្រាថ្នាមែនពិត នេះម្យ៉ាងឈ្មោះថា "ប្រាថ្នានូវហេតុឯណាមិនបាននូវហេតុនោះ ជាទុក្ខ" ។

**ជរាធម្មានំ ភិក្ខវេ សត្តានំ**


Websites: WatKhemaraRatanaram.org or WatKhmers.org

ម្នាលភិក្ខុទាំងឡាយ (សេចក្តីប្រាថ្នាកើតឡើង) ដល់សត្វទាំងឡាយ ដែលមានសេចក្តីចាស់ ជាធម្មតា...

**ព្យាធិធម្មានំ ភិក្ខវេ សត្តានំ**

ម្នាលភិក្ខុទាំងឡាយ (សេចក្តីប្រាថ្នាកើងឡើង) ដល់សត្វទាំងឡាយ ដែលមានសេចក្តីឈឺចាប់ ជាធម្មតា...

**មរណធម្មានំ ភិក្ខវេ សត្តានំ**

ម្នាលភិក្ខុទាំងឡាយ (សេចក្តីប្រាថ្នាកើតឡើង) ដល់សត្វទាំងឡាយ ដែលមានសេចក្តីស្លាប់ជាធម្មតា...

**សោកបរិទេវទុក្ខទោមនស្សុបាយាសធម្មានំ ភិក្ខវេ សត្តានំ ឯវំ ឥច្ឆា ឧប្បជ្ជតិ អហោ វត មយំ ន សោកបរិទេវទុក្ខទោមនស្សុបាយាស-សធម្មា អស្សាម ន ច វត នោ សោកបរិទេវទុក្ខទោមនស្សុបាយាសា អាគច្ឆេយ្យុន្តិ ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ ឥទម្បិ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ ៕**

ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាកើតឡើងដល់សត្វទាំងឡាយ ដែលមានសេចក្តីសោក សេចក្តីខ្សឹកខ្សួលសេចក្តីលំបាកកាយ សេចក្តីអាក់អន់ចិត្ត និងសេចក្តីខ្លោចផ្សាចិត្តជាធម្មតាយ៉ាងនេះថា "អើហ្ន៎! សូមឲ្យយើងទាំងឡាយ កុំគប្បីជាអ្នកមានសេចក្តីសោក សេចក្តីខ្សឹកខ្សួលសេចក្តីលំបាកកាយ សេចក្តីអាក់អន់ចិត្ត និងសេចក្តីខ្លោចផ្សាចិត្តជាធម្មតា ពុំនោះសោត សេចក្តីសោក សេចក្តីខ្សឹកខ្សួលសេចក្តីលំបាកកាយ សេចក្តីអាក់អន់ចិត្ត និងសេចក្តីខ្លោចផ្សាចិត្តទាំងឡាយ កុំគប្បីមកដល់យើងទាំងឡាយឡើង" ហើយហេតុនោះ ក៏សត្វទាំងឡាយមិនគប្បីដល់តាមសេចក្តីប្រាថ្នាមែនពិត នេះម្យ៉ាងឈ្មោះថា" ប្រាថ្នានូវហេតុឯណាមិនបាននូវហេតុនោះ ជាទុក្ខ" ។

**កតមេ ច ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "ដោយបង្រួមមកឧបាទានក្ខន្ធទាំងឡាយ ៥ ជាទុក្ខ" ?

**សេយ្យថីទំ** ? **រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ វិញ្ញាណុបាទានក្ខន្ធោ ឥមេ វុច្ចន្តិ ភិក្ខវេ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ៕**

ឧបាទានក្ខន្ធទាំង ៥ នេះដូចម្តេច ?

រូប ចាត់ជាឧបាទានក្ខន្ធ ១

វេទនា ចាត់ជាឧបាទានក្ខន្ធ ១

សញ្ញា ចាត់ជាឧបាទានក្ខន្ធ ១

សង្ខារ ចាត់ជាឧបាទានក្ខន្ធ ១

វិញ្ញាណ ចាត់ជាឧបាទានក្ខន្ធ ១

ម្នាលភិក្ខុទាំងឡាយ ទាំងនេះតថាគតចាត់ឲ្យឈ្មោះថា "ដោយបង្រួមមកឧបាទានក្ខន្ធទាំង ៥ ជាទុក្ខ" ។

**ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ ៕**

ម្នាល ភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "ទុក្ខអរិយសច្ចៈ" ។

**"ទុក្ខសច្ចំ និដ្ឋិតំ"**

(ទុក្ខសច្ចៈ ចប់)



Websites: WatKhemaraRatanaram.org or WatKhmers.org

# សមុទយសច្ច

**កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ** ?

ម្នាល ភិក្ខុទាំងឡាយ ដូចម្តេចហៅថា "ទុក្ខសមុទយអរិយសច្ចៈ" ?

**យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា តត្រតត្រាភិនន្ទិនី ។**

តណ្ហាឯណា ដែលមានកិរិយាធ្វើនូវភពថ្មីជាប្រក្រតីកើតរលត់ព្រម ដោយនន្ទិរាគៈត្រេកអរចំពោះក្នុងភព នោះៗឬក្នុងអារម្មណ៍នោះៗ ។

**សេយ្យថីទំ** ? **កាមតណ្ហា ភវតណ្ហា វិភវតណ្ហា ។**

តណ្ហានេះដូចម្តេច ? កាមតណ្ហា សេចក្តីប្រាថ្នាក្នុងកាមគុណ ១ ភវតណ្ហាសេចក្តីប្រាថ្នាក្នុងរូបភព និងអរូបភពដែលប្រកបដោយសស្សតទិដ្ឋិ ១ វិភវតណ្ហា សេចក្តីប្រាថ្នាដែលប្រកបដោយឧច្ឆេទទិដ្ឋិ ១ ។

**សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ ឧប្បជ្ជមានា ឧប្បជ្ជតិ កត្ថ និវិសមានា និវិសតិ** ?

ម្នាលភិក្ខុទាំងឡាយ តណ្ហានោះឯង កាលដែលកើតឡើងតើកើតឡើងក្នុងទីណា ? កាលដែលជាប់នៅ តើជាប់នៅ ក្នុងទីណា ?

**យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។**

អារម្មណ៍ឯណាក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើងរមែងកើតឡើងក្នុងអារម្មណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងអារម្មណ៍នោះ ។

**កិញ្ចិ លោកេ បិយរូបំ សាតរូបំ** ?

អារម្មណ៍អ្វីសោតក្នុងលោក ដែលមានសភាពគួរស្រឡាញ់មាន


Websites: WatKhemaraRatanaram.org or WatKhmers.org

សភាពគួរត្រេកអរ ?

**ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។**

ចក្ខុបសាទក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើងរមែងកើតឡើងក្នុងចក្ខុបសាទនោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងចក្ខុបសាទនោះ ។

**សោតំ លោកេ**...សោតបសាទ ក្នុងលោក...

**ឃានំ លោកេ**...ឃានបសាទ ក្នុងលោក...

**ជីវ្ហា លោកេ**....ជីវ្ហាបសាទ ក្នុងលោក...

**កាយោ លោកេ**...កាយបសាទ ក្នុងលោក...

**មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។**

មនោក្នុងលោកដែលមានភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលកើតឡើងរមែងកើតឡើងក្នុងមនោនោះ កាលដែលជាប់នៅក៏រមែងជាប់នៅក្នុង មនោនោះ។

**រូបា លោកេ**...រូបារម្មណ៍ ទាំងឡាយ ក្នុងលោក...

**សទ្ទា លោកេ**...សទ្ទារម្មណ៍ ទាំងឡាយ ក្នុងលោក...

**គន្ធា លោកេ**...គន្ធារម្មណ៍ ទាំងឡាយ ក្នុងលោក....

**រសា លោកេ**...រសារម្មណ៍ ទាំងឡាយ ក្នុងលោក...

**ផោដ្ឋព្វា លោកេ**...ផោដ្ឋព្វារម្មណ៍ទាំងឡាយក្នុងលោក...

**ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ**

ធម្មារម្មណ៍ទាំងឡាយក្នុងលោក ដែលមានសភាពគួរស្រឡាញ់


Websites: WatKhemaraRatanaram.org or WatKhmers.org

មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងធម្មារម្មណ៍ទាំងឡាយនោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងធម្មារម្មណ៍ទាំងឡាយនោះ ។

**ចក្ខុវិញ្ញាណំ លោកេ**...ចក្ខុវិញ្ញាណ ក្នុងលោក...

**សោតវិញ្ញាណំ លោកេ**...សោតវិញ្ញាណ ក្នុងលោក...

**ឃានវិញ្ញាណំ លោកេ**...ឃានវិញ្ញាណ ក្នុងលោក...

**ជិវ្ហាវិញ្ញាណំ លោកេ**...ជីវ្ហាវិញ្ញាណ ក្នុងលោក...

**កាយវិញ្ញាណំ លោកេ**...កាយវិញ្ញាណ ក្នុងលោក...

**មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។** មនោវិញ្ញាណ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងមនោវិញ្ញាណនោះកាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងមនោវិញ្ញាណនោះ ។

**ចក្ខុសម្ផស្សោ លោកេ**...ចក្ខុសម្ផស្ស ក្នុងលោក...

**សោតសម្ផស្សោ លោកេ**...សោតសម្ផស្ស ក្នុងលោក...

**ឃានសម្ផស្សោ លោកេ**...ឃានសម្ផស្ស ក្នុងលោក...

**ជិវ្ហាសម្ផស្សោ លោកកេ**...ជីវ្ហាសម្ផស្ស ក្នុងលោក...

**កាយសម្ផស្សោ លោកេ**...កាយសម្ផស្ស ក្នុងលោក...

**មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។**

មនោសម្ផស្សក្នុងលោក ដែលមានភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលកើតឡើងរមែងកើតឡើងក្នុងមនោសម្ផស្សនោះ កាលដែលជាប់នៅក៏រមែងជាប់នៅក្នុង មនោសម្ផស្សនោះ។


Websites: WatKhemaraRatanaram.org or WatKhmers.org

**ចក្ខុសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីចក្ខុសម្ផស្ស ក្នុងលោក...

**សោតសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីសោតសម្ផស្ស ក្នុងលោក...

**ឃានសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពី ឃានសម្ផស្ស ក្នុងលោក...

**ជិវ្ហាសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីជិវ្ហាសម្ផស្ស ក្នុងលោក...

**កាយសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីកាយសម្ផស្ស ក្នុងលោក...

**មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ៗ**

វេទនា ដែលកើតអំពីមនោសម្ផស្ស ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើងរមែងកើតឡើងក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនោះ កាលដែលជាប់នៅក៏រមែងជាប់ នៅក្នុងវេទនាដែលកើតអំពីមនោសម្ផស្សនោះ ។

**រូបសញ្ញា លោកេ...**

សេចក្តីសំគាល់នូវ សទ្ទារម្មណ៍ ក្នុងលោក...

**សទ្ទសញ្ញា លោកេ...**

សេចក្តីសំគាល់នូវ សទ្ទារម្មណ៍ ក្នុងលោក...

**គន្ធសញ្ញា លោកេ...**

សេចក្តីសំគាល់នូវ គន្ធារម្មណ៍ ក្នុងលោក...

**រសសញ្ញា លោកេ...**


Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្តីសំគាល់នូវ រសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វសញ្ញា លោកេ...**

សេចក្តីសំគាល់នូវ ផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។**

សេចក្តីសំគាល់នូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុង សេចក្តីសំគាល់នូវធម្មារម្មណ៍នោះ កាលដែលជាប់នៅក៏រមែងជាប់នៅក្នុងសេចក្តីសំគាល់នូវ ធម្មារម្មណ៍នោះ ។

**រូបសញ្ចេតនា លោកកេ...**

សេចក្តីចុះចិត្តក្នុង រូបារម្មណ៍ ក្នុងលោក...

**សទ្ទសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុង សទ្ទារម្មណ៍ ក្នុងលោក...

**គន្ធសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុង គន្ធារម្មណ៍ ក្នុងលោក...

**រសសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុង រសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុង ផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ។**

សេចក្តីចុះចិត្តក្នុងធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើងឡើង រមែង


Websites: WatKhemaraRatanaram.org or WatKhmers.org

កើតឡើងក្នុងសេចក្តីចុះចិត្ត ក្នុងធម្មារម្មណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងសេចក្តីចុះចិត្ត ក្នុងធម្មារម្មណ៍នោះ ។

**រូបតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងរូបារម្មណ៍ ក្នុងលោក...

**សទ្ទតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងសទ្ទារម្មណ៍ ក្នុងលោក...

**គន្ធតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងគន្ធារម្មណ៍ ក្នុងលោក...

**រសតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងរសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វតណ្ហា លោកេ...**

សេចក្តីចំណង់ ក្នុងផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ**

សេចក្តីចំណង់ក្នុងធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងសេចក្តីចំណង់ ក្នុងធម្មារម្មណ៍នោះកាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុងសេចក្តីចំណង់ក្នុងធម្មារម្មណ៍នោះ ។

**រូបវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរូបារម្មណ៍ ក្នុងលោក...

**សទ្ទវិតក្កោ លោកេ...**

សភាពត្រិះរិះនូវសទ្ទារម្មណ៍ ក្នុងលោក...

**គន្ធវិតក្កោ លោកេ...**


Websites: WatKhemaraRatanaram.org or WatKhmers.org

សភាពត្រិះរិះនូវគន្ធារម្មណ៍ ក្នុងលោក...

**រសវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វវិតក្កោ លោកេ..**

សភាពត្រិះរិះផោដ្ឋព្វារម្មណ៍ ក្នុងលោក...

**ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ៕**

សភាពត្រិះរិះ នូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគយរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើងឡើង ក្នុងសភាពត្រិះរិះនូវធម្មារម្មណ៍នោះ កាលដែលជាប់នៅក៏រមែងជាប់នៅក្នុងសភាពត្រិះរិះ នូវធម្មារម្មណ៍នោះ ។

**រូបវិចារោ លោកេ...**

សភាពពិចារណា នូវរូបារម្មណ៍ ក្នុងលោក...

**សទ្ទវិចារោ លោកេ...**

សភាពពិចារណា នូវសទ្ទារម្មណ៍ ក្នុងលោក...

**គន្ធវិចារោ លោកេ...**

សភាពពិចារណា នូវគន្ធារម្មណ៍ ក្នុងលោក...

**រសវិចារោ លោកេ...**

សភាពពិចារណា នូវរសារម្មណ៍ ក្នុងលោក...

**ផោដ្ឋព្វវិចារោ លោកេ...**

សភាពពិចារណា នូវផោដ្ឋព្វារម្មណ៍ ក្នុងលោក....

**ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា ឧប្បជ្ជមានា ឧប្បជ្ជតិ ឯត្ថ និវិសមានា និវិសតិ ៕**


Websites: WatKhemaraRatanaram.org or WatKhmers.org

សភាពពិចារណា នូវធម្មារម្មណ៍ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលកើតឡើង រមែងកើតឡើងក្នុងសភាពពិចារណានូវធម្មារម្មណ៍នោះ កាលដែលជាប់នៅ ក៏រមែងជាប់នៅក្នុង សភាពពិចារណានូវធម្មារម្មណ៍នោះ ។

**ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ**

ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "ទុក្ខសមុទយអរិយសច្ចៈ" ។

**"សមុទយសច្ចំ និដ្ឋិតំ"**

(សមុទយសច្ចៈ ចប់)

# និរោធសច្ច

**កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្ដេចហៅថា "ទុក្ខនិរោធ អរិយសច្ចៈ" ?

**យោ តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ ចាគោ បដិនិស្សគ្គោ មុត្តិ អនាលយោ ។**

កិរិយារលត់ទៅ នៃតណ្ហានោះ មិនមានសេសសល់ដោយអរិយមគ្គឯណា កិរិយាលះបង់នូវតណ្ហានោះឯណា កិរិយារលាស់ចេញចាកតណ្ហានោះឯណា កិរិយារួចចាកតណ្ហានោះឯណា សេចក្ដីមិនមានអាល័យក្នុងតណ្ហានោះឯណា (កិរិយារលត់ទៅនៃតណ្ហា ជាដើមនោះហៅថា "ទុក្ខនិរោធអរិយសច្ចៈ" ) ។

**សា ខោ បនេសា ភិក្ខវេ តណ្ហា កត្ថ បហិយ្យមានា បហិយ្យតិ កត្ថ និរុជ្ឈមានា និរុជ្ឈតិ** ?


Websites: WatKhemaraRatanaram.org or WatKhmers.org

ម្នាលភិក្ខុទាំងឡាយ តណ្ហានោះសោត កាលដែលលោកលះបង់ តើលះបង់ក្នុងទីណា? កាលដែលរលត់ទៅវិញ តើរលត់ទៅក្នុងទីណា ?

**យំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ៕**

អារម្មណ៍ឯណាក្នុងលោកដែលមានសភាព គួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់រមែងលះបង់ ក្នុងអារម្មណ៍នោះ កាលដែលរលត់ទៅវិញក៏រមែងរលត់ទៅក្នុងអារម្មណ៍នោះ ។

**កិញ្ចិ លោកេ បិយរូបំ សាតរូបំ** ?

អារម្មណ៍អ្វីសោតក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ ?

**ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ៕**

ចក្ខុសាទ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់រមែងលះបង់ ក្នុងចក្ខុបសាទនោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុង ចក្ខុបសាទនោះ។

**សោតំ លោកេ**...សោតបសាទ ក្នុងលោក...

**ឃានំ លោកេ**...ឃានបសាទ ក្នុងលោក...

**ជិវ្ហា លោកេ**...ជីវ្ហាបសាទ ក្នុងលោក...

**កាយោ លោកេ**...កាយបសាទ ក្នុងលោក...

**មនោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ៕**


Websites: WatKhemaraRatanaram.org or WatKhmers.org

មនោក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរតណ្ហានោះ កាលដែលលោកលះបង់ រមែងលះបង់ក្នុងមនោនោះ កាលដែលរលត់ទៅវិញក៏រមែង រលត់ទៅក្នុង មនោនោះ ។

**រូបា លោកេ**...រូបារម្មណ៍ទាំងឡាយ ក្នុងលោក...

**សទ្ទា លោកេ**...សទ្ទារម្មណ៍ទាំងឡាយ ក្នុងលោក...

**គន្ធា លោកេ**... គន្ធារម្មណ៍ទាំងឡាយ ក្នុងលោក...

**រសា លោកេ**... រសារម្មណ៍ទាំងឡាយ ក្នុងលោក...

**ផោដ្ឋព្វា លោកេ**...ផោដ្ឋព្វារម្មណ៍ទាំងឡាយ ក្នុងលោក...

**ធម្មា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ៕**

ធម្មារម្មណ៍ទាំងឡាយក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងធម្មារម្មណ៍ទាំងឡាយនោះកាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុង ធម្មារម្មណ៍ទាំងឡាយនោះ ។

**ចក្ខុវិញ្ញាណំ លោកេ**... ចក្ខុវិញ្ញាណក្នុងលោក...

**សោតវិញ្ញាណំ លោកេ**...សោតវិញ្ញាណក្នុងលោក...

**ឃានវិញ្ញាណំ លោកេ**...ឃានវិញ្ញាណក្នុងលោក...

**ជិវ្ហាវិញ្ញាណំ លោកេ**...ជីវ្ហាវិញ្ញាណក្នុងលោក...

**កាយវិញ្ញាណំ លោកេ**...កាយវិញ្ញាណក្នុងលោក...

**មនោវិញ្ញាណំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ៕**

មនោវិញ្ញាណក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់រមែងលះបង់ក្នុងមនោ


Websites: WatKhemaraRatanaram.org or WatKhmers.org

វិញ្ញាណនោះ ។

**ចក្ខុសម្ផស្សោ លោកេ**...ចក្ខុសម្ផស្សក្នុងលោក...

**សោតសម្ផស្សោ លោកេ**...ឃានសម្ផស្សក្នុងលោក...

**ឃានសម្ផស្សោ លោកេ**...ឃានសម្ផស្សក្នុងលោក...

**ជិវ្ហាសម្ផស្សោ លោកេ**...ជិវ្ហាសម្ផស្សក្នុងលោក...

**កាយសម្ផស្សោ លោកេ**...កាយសម្ផស្សក្នុងលោក...

**មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ៕**

មនោវិញ្ញាណក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់រមែងលះបង់ក្នុងមនោវិញ្ញាណនោះ ។

**ចក្ខុសម្ផស្សោ លោកេ**...ចក្ខុសម្ផស្សក្នុងលោក...

**សោតសម្ផស្សោ លោកេ**...សោតសម្ផស្សក្នុងលោក...

**ឃានសម្ផស្សោ លោកេ**...ឃានសម្ផស្សក្នុងលោក...

**ជិវ្ហាសម្ផស្សោ លោកេ**...ជិវ្ហាសម្ផស្សក្នុងលោក...

**កាយសម្ផស្សោ លោកេ**...កាយសម្ផស្សក្នុងលោក...

**មនោសម្ផស្សោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ៕**

មនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់មានសភាពគួរត្រេកអរ តណ្ហានោះ កាលដែលលោកលះបង់រមែងលះបង់ក្នុងមនោសម្ផស្សនោះ កាលដែលរលត់ទៅវិញក៏រមែងរលត់ទៅ ក្នុងមនោសម្ផស្សនោះ ។


Websites: WatKhemaraRatanaram.org or WatKhmers.org

**ចក្ខុសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីចក្ខុសម្ផស្សក្នុងលោក...

**សោតសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីសោតសម្ផស្សក្នុងលោក...

**ឃានសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតឃានសម្ផស្សក្នុងលោក...

**ជិវ្ហាសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីជិវ្ហាសម្ផស្សក្នុងលោក...

**កាយសម្ផស្សជា វេទនា លោកេ...**

វេទនាដែលកើតអំពីកាយសម្ផស្សក្នុងលោក...

**មនោសម្ផស្សជា វេទនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និវិសមានា និវិសតិ ។**

វេទនាដែលកើតអំពីមនោសម្ផស្សក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងវេទនា ដែលកើតអំពីមនោសម្ផស្សនោះ កាលដែលរលត់ទៅវិញក៏ រមែងរលត់ទៅក្នុងវេទនា ដែលកើតអំពីមនោសម្ផស្សនោះ ។

**រូបសញ្ញា លោកេ...**

សេចក្តីសំគាល់នូវរូបារម្មណ៍ក្នុងលោក...

**សទ្ទសញ្ញា លោកេ...**

សេចក្តីសំគាល់នូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធសញ្ញា លោកេ...**

សេចក្តីសំគាល់នូវគន្ធារម្មណ៍ក្នុងលោក...

**រសសញ្ញា លោកេ...**


Websites: WatKhemaraRatanaram.org or WatKhmers.org

សេចក្តីសំគាល់នូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វសញ្ញា លោកេ...**

សេចក្តីសំគាល់នូវផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មសញ្ញា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និវិសមានា និវិសតិ ។**

សេចក្តីសំគាល់នូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងសេចក្តីសំគាល់នូវធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសេចក្តីសំគាល់នូវធម្មារម្មណ៍នោះ ។

**រូបសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុងរូបារម្មណ៍ក្នុងលោក...

**សទ្ទសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុងសទ្ទារម្មណ៍ក្នុងលោក...

**គន្ធសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុងគន្ធារម្មណ៍ក្នុងលោក...

**រសសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុងរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វសញ្ចេតនា លោកេ...**

សេចក្តីចុះចិត្តក្នុងផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មសញ្ចេតនា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និវិសមានា និវិសតិ ។**

សេចក្តីចុះចិត្តក្នុងធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់


Websites: WatKhemaraRatanaram.org or WatKhmers.org

រមែងលះបង់ក្នុងសេចក្តីចុះចិត្តក្នុងធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសេចក្តីចុះចិត្តក្នុងធម្មារម្មណ៍នោះ ។

**រូបតណ្ហា លោកេ...**

សេចក្តីចំណង់ក្នុងរូបារម្មណ៍ក្នុងលោក...

**សទ្ទតណ្ហា លោកេ...**

សេចក្តីចំណង់ក្នុងសទ្ទារម្មណ៍ក្នុងលោក...

**គន្ធតណ្ហា លោកេ...**

សេចក្តីចំណង់ក្នុងគន្ធារម្មណ៍ក្នុងលោក...

**រសតណ្ហា លោកេ...**

សេចក្តីចំណង់ក្នុងរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វតណ្ហា លោកេ...**

សេចក្តីចំណង់ក្នុងផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មតណ្ហា លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និរុជ្ឈមានា និរុជ្ឈតិ ។**

សេចក្តីចំណង់ក្នុងធម្មារណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរតណ្ហានោះ កាលដែលលោកលះបង់រមែងលះបង់ក្នុងសេចក្តីចំណង់ ក្នុងធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញក៏រមែងរលត់ទៅក្នុងសេចក្តីចំណង់ ក្នុងធម្មារម្មណ៍នោះ ។

**រូបវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរូបារម្មណ៍ក្នុងលោក...

**សទ្ទវិតក្កោ លោកេ...**

សភាពត្រិះរិះនូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធវិតក្កោ លោកេ...**

សភាពត្រិះរិះនូវគន្ធារម្មណ៍ក្នុងលោក...

**រសវិតក្កោ លោកេ...**

សភាពត្រិះរិះនូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វវិតក្កោ លោកេ...**

សភាពត្រិះរិះផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មវិតក្កោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និវិសមានា និវិសតិ ៕**

សភាពត្រិះរិះនូវធម្មារម្មណ៍ ក្នុងលោកដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរ តណ្ហានោះកាលដែលលោកលះបង់ រមែងលះបង់ក្នុងសភាពត្រិះរិះនូវធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសភាពត្រិះរិះនូវធម្មារម្មណ៍នោះ ។

**រូបវិចារោ លោកេ...**

សភាពពិចារណានូវរូបារម្មណ៍ក្នុងលោក...

**រូបវិចារោ លោកេ...**

សភាពពិចារណានូវសទ្ទារម្មណ៍ក្នុងលោក...

**គន្ធវិចារោ លោកេ...**

សភាពពិចារណានូវគន្ធារម្មណ៍ក្នុងលោក...

**រសវិចារោ លោកេ...**

សភាពពិចារណានូវរសារម្មណ៍ក្នុងលោក...

**ផោដ្ឋព្វវិចារោ លោកេ...**

សភាពពិចារណានូវផោដ្ឋព្វារម្មណ៍ក្នុងលោក...

**ធម្មវិចារោ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហិយ្យមានា បហិយ្យតិ ឯត្ថ និវិសមានា និវិសតិ ៕**


Websites: WatKhemaraRatanaram.org or WatKhmers.org

សភាពពិចារណានូវធម្មារម្មណ៍ ក្នុងលោក ដែលមានសភាពគួរស្រឡាញ់ មានសភាពគួរត្រេកអរតណ្ហានោះ កាលដែលលោកលះបង់ រមែងលះបង់ក្នុងភាពពិចារណា នូវធម្មារម្មណ៍នោះ កាលដែលរលត់ទៅវិញ ក៏រមែងរលត់ទៅក្នុងសភាពពិចារណានូវ ធម្មារម្មណ៍នោះ ។

**ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ**

ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "ទុក្ខនិរោធ អរិយសច្ចៈ" ។

**"និរោធសច្ចំ និដ្ឋិតំ"**

(និរោធសច្ចៈ ចប់)



Websites: WatKhemaraRatanaram.org or WatKhmers.org

# មគ្គសច្ច

**កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ចៈ" ?

**អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ ។**

នេះឯងគឺ ផ្លូវអរិយមគ្គដែលប្រកបដោយអង្គ ៨ ប្រការ ។

**សេយ្យថីទំ** ? **សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។**

អរិយមគ្គ នេះដូចម្តេច ?

ប្រាជ្ញាយល់ឃើញដោយប្រពៃ ១

សេចក្តីត្រិះរិះ ដោយប្រពៃ ១

ពោលពាក្យសំដី ដោយប្រពៃ ១

ការងារប្រព្រឹត្តទៅដោយប្រពៃ ១

កិរិយាចិញ្ចឹមជីវិតដោយប្រពៃ ១

សេចក្តីព្យាយាមដោយប្រពៃ ១

សេចក្តីរឭកឃើញដោយប្រពៃ ១

សេចក្តីសម្រឹង(តម្កល់)ចិត្តដោយប្រពៃ ១។

**កតមា ច ភិក្ខវេ សម្មាទិដ្ឋិ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "ប្រាជ្ញាយល់ឃើញដោយប្រពៃ" ?

**យំ ខោ ភិក្ខវេ ទុក្ខេ ញាណំ ទុក្ខសមុទយេ ញាណំ ទុក្ខនិរោធ ញាណំ ទុក្ខនិរោធគាមិនិយា បដិបទាយ ញាណំ អយំ វុច្ចតិ ភិក្ខវេ**


Websites: WatKhemaraRatanaram.org or WatKhmers.org

**សម្មាទិដ្ឋិ ។**

ម្នាលភិក្ខុទាំងឡាយ ប្រាជ្ញាដឹងច្បាស់ក្នុងកងទុក្ខណាប្រាជ្ញាដឹងច្បាស់ក្នុងធម៌ ជាដែនកើតនៃទុក្ខឯណា ប្រាជ្ញាដឹងច្បាស់ក្នុងធម៌ជាទីរលត់ទៅនៃទុក្ខឯណា ប្រាជ្ញាដឹងច្បាស់ក្នុងដំណើរដែលទៅកាន់ធមឥជាទីរលត់ទៅនៃទុក្ខឯណា ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "ប្រាជ្ញាយល់ឃើញដោយប្រពៃ" ។

**កតមោ ច ភិក្ខវេ សម្មាសង្កប្បោ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីត្រិះរិះដោយប្រពៃ"?

**នេក្ខម្មសង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ អយំ វុច្ចតិ ភិក្ខវេ សម្មាសង្កប្បោ ។**

សេចក្តីត្រិះរិះ ដើម្បីចេញចាកកាម ១

សេចក្តីត្រិះរិះ ដើម្បីមិនព្យាបាទ ១

សេចក្តីត្រិះរិះ ដើម្បីមិនបៀតបៀន ១

ម្នាលភិក្ខុទាំងឡាយនេះ តថាគតចាត់ឲ្យឈ្មោះថា "សេចក្តីត្រិះរិះដោយប្រពៃ" ។

**កតមា ច ភិក្ខវេ សម្មាវាចា ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "ពោលពាក្យសំដីដោយប្រពៃ" ?

**មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាវាចា ។**

ចេតនាវៀរចាកពោលនូវពាក្យមិនពិត ១

ចេតនាវៀរចាកសំដីញុះញង់ស៊កសៀត ១

ចេតនាវៀរចាកសំដីត្រគោះខ្ទីខ្ទា ១

ចេតនាវៀរចាកសំដីរោយរាយឥតប្រយោជន៍ ១

ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "ពោលពាក្យសំដីដោយប្រពៃ" ។

**កតមោ ច ភិក្ខវេ សម្មាកម្មន្តោ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "ការងារប្រព្រឹត្តទៅដោយប្រពៃ" ?

**បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី អយំ វុច្ចតិ ភិក្ខវេ សម្មាកម្មន្តោ ។**

ចេតនាវៀរចាកកិរិយាញុំាងសត្វមានជីវិតឲ្យធ្លាក់ចុះឆាប់ ១

ចេតនាវៀរចាកកិរិយាកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ ១

ចេតនាវៀរចាកកិរិយាប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១

ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "ការងារប្រព្រឹត្តទៅដោយប្រពៃ" ។

**កតមោ ច ភិក្ខវេ សម្មាអាជីវោ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "កិរិយាចិញ្ចឹមជីវិតដោយប្រពៃ" ?

**ឥធ ភិក្ខវេ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិតំ កប្បេតិ អយំ វុច្ចតិ ភិក្ខវេ សម្មាអាជីវោ ។**

ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់នូវកិរិយាចិញ្ចឹមជីវិតខុសហើយសម្រេចនូវការចិញ្ចឹមជីវិតដោយព្យាយាមជាគ្រឿងរស់នៅដោយប្រពៃ ម្នាលភិក្ខុទាំងឡាយនេះតថាគតចាត់ឲ្យឈ្មោះថា "កិរិយាចិញ្ចឹមជីវិតដោយប្រពៃ" ។



Websites: WatKhemaraRatanaram.org or WatKhmers.org

**កតមោ ច ភិក្ខវេ សម្មាវាយាមោ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីព្យាយាមដោយប្រពៃ" ?

**ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ។ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ។ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាវាយាមោ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ញុំាងឆន្ទឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាមផ្គងចិត្តទុកតាំងព្យាយាមមាំដើម្បីញុំាងធម៌ទាំងឡាយជាអកុសលដ៏លាមក ដែលមិនទាន់កើតឡើង កុំឲ្យកើតឡើងបាន។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាមផ្គងចិត្តទុកតាំងព្យាយាមមាំ ដើម្បីលះបង់នូវធម៌ទាំងឡាយជាអកុសលដ៏លាមកដែលកើងឡើងហើយ។ ញុំាងឆន្ទៈឲ្យកើត ប្រឹងប្រែងប្រារព្ធនូវព្យាយាមផ្គងចិត្តទុកតាំងព្យាយាមមាំ ដើម្បីញុំាងធម៌ទាំងឡាយជាកុសលដែលមិនទាន់កើតឲ្យកើតឡើង ។ ញុំាងឆន្ទៈឲ្យកើតប្រឹងប្រែងប្រារព្ធនូវព្យាយាម ផ្គងចិត្តទុកតាំងព្យាយាមមាំដើម្បីញុំាងធម៌ទាំងឡាយជាកុសល ដែលកើតឡើងហើយឲ្យបានស្ថិតស្ថេរកុំឲ្យភ្លេចភ្លាំងទៅវិញ ឲ្យបានចម្រើនធំទូលាយពេញបរិបូរណ៍ក្រៃលែងឡើង ។ ម្នាលភិក្ខុទាំងឡាយនេះតថាគតចាត់ឲ្យឈ្មោះ

ថា "សេចក្តីព្យាយាមដោយប្រពៃ" ។

**កតមា ច ភិក្ខវេ សម្មាសតិ ?**

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីរឭកឃើញដោយប្រពៃ" ?

**ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អយំ វុច្ចតិ ភិក្ខវេ សម្មាសតិ ។**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វមានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវ អភិជ្ឈា និងទោមនុស្សក្នុងលោក ។ ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវ អភិជ្ឈ និងទោមនស្សក្នុងលោក ។ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តមានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វមានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក។ ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់បណ្តេញបង់នូវ អភិជ្ឈានិងទោមនស្សក្នុងលោក។ ម្នាលភិក្ខុទាំងឡាយនេះ តថាគតចាត់ឲ្យឈ្មោះថា "សេចក្តីរឭកឃើញដោយប្រពៃ" ។


Websites: WatKhemaraRatanaram.org or WatKhmers.org

**កតមោ ច ភិក្ខវេ សម្មាសមាធិ** ?

ម្នាលភិក្ខុទាំងឡាយ ដូចម្តេចហៅថា "សេចក្តីសម្រឹងចិត្តដោយប្រពៃ" ?

**ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ៗ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ៗ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ៗ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ៗ អយំ វុច្ចតិ ភិក្ខវេ សម្មាសមាធិ ៗ**

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ហើយចាកកាមទាំងឡាយ ស្ងាត់ហើយចាកធម៌ទាំងឡាយជាអកុសលចូលដល់នូវបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិ និងសុខៈ ដែលកើតអំពីវិវេក ។ រម្ងាប់បង់នូវវិតក្កៈ និងវិចារៈទាំងឡាយហើយចូលដល់នូវទុតិយជ្ឈាន ដែលមានសទ្ធាដ៏ថ្លាផូរផង់ តាំងនៅព្វដ៏ខាងក្នុងជាគ្រឿងញ៉ាំងសមាធិចិត្តយ៉ាងឯកឲ្យចម្រើនឡើង មិនមានវិតក្កៈ មិនមានវិចារៈ មានតែបិតិ និសុខៈដែលកើតអំពីសមាធិ។ ជាអ្នកព្រងើយកន្តើយ ខ្ពើមរអើមចាកបីតិ(ទាំងស្ងប់ចាកវិតក្កៈ និវិចារៈ) ផង មានស្មារតីមានប្រាជ្ញាដឹងសព្វផង សោយនូវសេចក្តីសុខដោយកាយផង ព្រះអរិយបុគ្គលដែលបាននូវតតិយជ្ឈានឯណា "ថាជាអ្នកព្រងើយកន្តើយ មាន


Websites: WatKhemaraRatanaram.org or WatKhmers.org

ស្មារតី មានប្រក្រតីនៅជាសុខ″ ក៏ចូលដល់នូវតតិយជ្ឈាននោះ ។ ចូលដល់នូវចតុត្ថជ្ឈាន មានស្មារតីដ៏ស្អាតដែលកើតអំពី ឧបេក្ខា ឥតទុក្ខឥតសុខ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផងព្រោះអស្តង្គតរលត់ទៅនៃសោមនស្ស និងទោមនស្សទាំងឡាយអំពីមុនផង ។ ម្នាលភិក្ខុទាំងឡាយនេះតថាគតចាត់ឲ្យឈ្មោះថា "សេចក្តីសម្រឹងចិត្តដោយប្រពៃ″ ។

**ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចំ ៕**

ម្នាលភិក្ខុទាំងឡាយ នេះតថាគតចាត់ឲ្យឈ្មោះថា "ទុក្ខនិរោធគាមិនីបដិបទា អរិយសច្ចៈ″ ។

**"មគ្គសច្ចំ និដ្ឋិតំ"**

(មគ្គសច្ចៈ ចប់)

**ឥតិ អជ្ឈត្តំ វា ធម្មេសុ ធម្មានុបស្សី វិហរតិ ពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ អជ្ឈត្តពហិទ្ធា វា ធម្មេសុ ធម្មានុបស្សី វិហរតិ សមុទយធម្មានុបស្សី វា ធម្មេសុ វិហរតិ វយធម្មានុបស្សី វា ធម្មេសុ វិហរតិ សមុទយវយធម្មានុបស្សី វា ធម្មេសុ វិហរតិ ៕ អត្ថិ ធម្មាតិ វា បនស្ស សតិ បច្ចុបដ្ឋិតា ហោតិ យាវទេវ ញាណមត្តាយ បតិស្សតិមត្តាយ អនិស្សិតោ ច វិហរតិ ន ច កិញ្ចិ លោកេ ឧបាទិយតិ៕**

ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្នុង (របស់ខ្លួន) ដូច្នេះផងពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាខាងក្រៅ (របស់អ្នកដទៃ) ផងពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំង


Websites: WatKhemaraRatanaram.org or WatKhmers.org

ឡាយ ទាំងខាងក្នុង ទាំងខាងក្រៅផង ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងក្នុងធម៌ទាំងឡាយផង ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយផង ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើងទាំងធម៌ដែលសូន្យទៅក្នុងធម៌ទាំងឡាយផង ។ ម្យ៉ាងទៀត ស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើងចំពោះថា "គ្រាន់តែជាធម៌ទាំងឡាយ (មិនមែនសត្វ មិនមែនបុគ្គល មិនមែនស្ត្រី និងបុរសជាដើម) ល្មមតែកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះផង" ។ មានចិត្តមិនអាស្រ័យនូវដោយតណ្ហានិងទិដ្ឋិផងមិនប្រកៀកប្រកាន់អ្វី តិចតួចក្នុងលោកផង។

**ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ ចតូសុ អរិយសច្ចេសុ ២**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ អរិយសច្ចៈ ៤ ។

**"សច្ចបព្វំ និដ្ឋិតំ"**

(ពួកសច្ចៈ ចប់)

**"ធម្មានុបស្សនាសតិបដ្ឋានំ និដ្ឋិតំ"**

((**ធម្មានុបស្សនាសតិបដ្ឋាន ចប់**))


Websites: WatKhemaraRatanaram.org or WatKhmers.org

## សតិបដ្ឋានភាវនានិសង្ស

**យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្ត វស្សានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគមិតា ។**

ម្នាលភិក្ខុទាំងឡាយបើបុគ្គលណាមួយ (ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី) គប្បីចម្រើននូវសតិបដ្ឋានទាំងឡាយ ៤ នេះតាមលំដាប់នៃវិធីចម្រើនដែលតថាគតបានពោលមក ហើយយ៉ាងនេះអស់ឆ្នាំទាំងឡាយ ៧ បណ្តាផលទាំងឡាយពីរផលណាមួយ គង់នឹងបានសម្រេចនូវភាពជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែកពុំនោះសោតបើមានឧបាទានក្ខន្ធសេសសល់នៅក៏គង់នឹងបានសម្រេច នូវភាពជាព្រះអនាគាមិបុគ្គល មិនខានឡើយ ។

**តិដ្ឋន្តុ ភិក្ខវេ សត្ត វស្សានិ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ វ ឯវំ ភាវេយ្យ ឆ វស្សានិ ។ បញ្ច វស្សានិ ។ ចត្តារិ វស្សានិ ។ តីណិ វស្សានិ ។ ទ្វេ វស្សានិ ។ ឯកំ វស្សំ ។ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។**

ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ឆ្នាំទាំងឡាយ ៧ ឡើយ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ (ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី) គប្បីចម្រើននូវសតិបដ្ឋានទាំងឡាយ ៤ នេះតាមលំដាប់នៃវិធីចម្រើនដែលតថាគតបានពោលមកហើយយ៉ាងនេះ អស់ឆ្នាំទាំងឡាយ ៦ ។ អស់ឆ្នាំទាំងឡាយ ៥ ។ អស់ឆ្នាំទាំងឡាយ ៤ ។ អស់ឆ្នាំទាំងឡាយ ៣ ។ អស់ឆ្នាំទាំងឡាយ ២ ។ អស់ឆ្នាំទាំងឡាយ ១ ។ បណ្តាផលទាំង


Websites: WatKhemaraRatanaram.org or WatKhmers.org

ឡាយពីរ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះ តាមប្រាថ្នាដោយពិត គឺនឹងបានសម្រេចនូវភាពជាព្រះអរហន្ត ក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅ ក៏គង់នឹងបានសម្រេចនូវភាពជាព្រះអនាគាមិបុគ្គល មិនខានឡើយ ។

**តិដ្ឋតុ ភិក្ខវេ ឯកំ វស្សំ ៕ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្ត មាសានិ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ៕**

ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ឆ្នាំ ១ ឡើយ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណាមួយ (ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសក្តី ឧបាសិកាក្តី) គប្បីចម្រើននូវសតិបដ្ឋានទាំងឡាយ ៤ នេះតាមលំដាប់នៃវិធីចម្រើនដែលតថាគត បានពោលមកហើយយ៉ាងនេះ អស់ខែទាំងឡាយ ៧ បណ្តាផលទាំងឡាយ ពីរ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះតាមប្រាថ្នាដោយពិតគឺនឹងបានសម្រេច នូវភាពជាព្រះអរហន្តក្នុងបច្ចុប្បន្នទាន់ភ្នែក ពុំនោះសោតបើមានឧបាទានក្ខន្ធសេសសល់នៅក៏គង់នឹងបានសម្រេចនូវភាពជាព្រះអនាគាមិបុគ្គលមិនខានឡើយ ។

**តិដ្ឋន្តុ ភិក្ខវេ សត្ត មាសានិ ៕ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ ឆ មាសានិ ៕ បញ្ច មាសានិ ៕ ចត្តារិ មាសានិ ៕ តីណិ មាសានិ ៕ ទ្វេ មាសានិ ៕ ឯកំ មាសំ ៕ អឌ្ឍមាសំ ៕ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ៕**

ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់ខែទាំងឡាយ ៧ ឡើយ។ ម្នាល ភិក្ខុទាំងឡាយ បើបុគ្គលណាមួយ (ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសិកាក្តី ឧបាសិកាក្តី) គប្បីចម្រើននូវសតិបដ្ឋានទាំងឡាយ ៤ នេះតាមលំដាប់នៃ

វិធីចម្រើនដែលតថាគតបានពោលមកហើយយ៉ាងនេះ អស់ខែទាំងឡាយ ៦ ។ អស់ខែទាំងឡាយ ៥។ អស់ខែទាំងឡាយ ៤។ អស់ខែទាំងឡាយ ៣។ អស់ខែទាំងឡាយ ២។ អស់ខែ ១។ អស់កន្លះនៃខែ។ បណ្តាផល ទាំងឡាយ ២ ផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះតាម ប្រាថ្នាដោយពិតគឺនឹងបានសម្រេចនូវភាពជាព្រះអរហន្តក្នុង បច្ចុប្បន្នទាន់ ភ្នែកពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់នៅក៏គង់នៅបាន សម្រេចនូវភាពជាព្រះអនាគាមិបុគ្គល មិនខានឡើយ ។

**តិដ្ឋតុ ភិក្ខវេ អឌ្ឍមាសោ ។ យោ ហិ កោចិ ភិក្ខវេ ឥមេ ចត្តារោ សតិបដ្ឋានេ ឯវំ ភាវេយ្យ សត្តាហំ តស្ស ទ្វិន្នំ ផលានំ អញ្ញតរំ ផលំ បាដិកង្ខំ ទិដ្ឋេវ ធម្មេ អញ្ញា សតិ វា ឧបាទិសេសេ អនាគាមិតា ។**

ម្នាលភិក្ខុទាំងឡាយ កុំថាដល់ទៅអស់កន្លះនៃខែឡើយ។ ម្នាលភិក្ខុ ទាំងឡាយ បើបុគ្គលណាមួយ (ទោះភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកា ក្តី) គប្បីចម្រើននូវ សតិបដ្ឋានទាំងឡាយ ៤ នេះតាមលំដាប់នៃវិធីចម្រើន ដែលតថាគតបានពោលមក ហើយយ៉ាងនេះអស់ថ្ងៃ ៧ បណ្តាលផល ទាំងឡាយពីរផលណាមួយ គង់នឹងបានសម្រេចដល់បុគ្គលនោះ តាម ប្រាថ្នាដោយពិត គឺនឹងបានសម្រេចនូវភាពជាព្រះអរហន្តក្នុងបច្ចុប្បន្នទាន់ ភ្នែក ពុំនោះសោត បើមានឧបាទានក្ខន្ធសេសសល់សល់នៅ ក៏គង់នឹង បានសម្រេចនូវភាពជាព្រះអនាគាមិបុគ្គលមិនខានឡើយ ។

**ឯកាយនោ អយំ ភិក្ខវេ មគ្គោ សត្តានំ វិសុទ្ធិយា សោកបរិទេ-វានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ យទិទំ ចត្តារោ សតិបដ្ឋានាតិ ។**

ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិបដ្ឋានទាំងឡាយ ៤ នេះជាផ្លូវមូល តែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីស្អាតវិសេសដល់សត្វទាំងឡាយ ដើម្បី កន្លងបង់នូវសោក និងខ្សឹកខ្សួល រំជួលចិត្តទាំងឡាយ ដើម្បីអស្តង្គតរលត់


Websites: WatKhemaraRatanaram.org or WatKhmers.org

ទៅនៃទុក្ខ និងទោមនស្សទាំងឡាយ ដើម្បីដល់នូវអរិយមគ្គ ជាធម៌ស្រោចស្រង់សត្វ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិញ្វន ។

**ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។**

ពាក្យឯណាដែលតថាគតបានពោលហើយថា "សាសនារបស់តថាគត ជាគុណសម្រាប់ស្រោចស្រង់សត្វ" ដូច្នេះពាក្យនោះតថាគតពោលហើយ ព្រោះអាស្រ័យនូវផ្លូវដ៏ប្រសើរគឺសតិបដ្ឋានទាំង ៤ នេះ ។

**ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។**

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សំដែងនូវសតិបដ្ឋានសូត្រនេះចប់ហើយ ភិក្ខុទាំងឡាយនោះក៏មានចិត្តត្រេកអរចំពោះភាសិតនៃព្រះដ៏មានព្រះភាគ (ទាំងអស់អង្គ) ។

**"សតិបដ្ឋានសុត្តំ និដ្ឋិតំ ទសមំ"**

((សតិបដ្ឋានសូត្រទី ១០ ចប់))

នៅទីបំផុតនៃសតិបដ្ឋានសុត្តទេសនានេះ ភិក្ខុបានលុះព្រះអរហត្តចំនួន បីម៉ឺនព្រះអង្គ

**សូមអនុមោទនា !!!**

**ចប់**


Websites: WatKhemaraRatanaram.org or WatKhmers.org

# សតិប្បដ្ឋានសូត្រ

សតិប្បដ្ឋានសូត្រ